# ឱវាទព្រះសាស្តាភាគទី១
# បណ្តាំលោកគ្រូ

# ពាក្យប្រារព្ធ

សៀវភៅនេះ ជាស្នាដៃលើកទី២ ដែលខ្ញុំព្រះករុណា នាងខ្ញុំ បានសរសេរបន្តពីសៀវភៅបណ្តាំលោកគ្រូ ជាស្នាដៃលើកទី១ ។ បានបោះពុម្ពចែកជាធម្មទានរួច ជាស្ថាពរហើយ ក្នុងចំនួន ៦៦០០ក្បាល តម្លៃ ២.០០០ដុល្លារអាមេរិក ។

ក្នុងឱកាសនេះផងដែរ ខ្ញុំព្រះករុណា នាងខ្ញុំសូមអភ័យទោស ចំពោះការខុសឆ្គងដោយពាក្យដែលបាន ប្រមូលរៀបរៀង ឬដោយប្រការណាក្នុងសៀវភៅ បណ្តាំលោកគ្រូក្តី ក្នុងសៀវភៅនេះក្តី ព្រោះការចេះដឹងមានតិចតួច ។ តាមសេចក្តីពិត ខ្ញុំព្រះករុណានាងខ្ញុំ គ្មានបំណងនឹងបោះពុម្ពចេញជាសៀវភៅឡើយ គឺមានបំណង គ្រាន់តែព្យាយាមសរសេរកត់ត្រាទុក ដើម្បីជាប្រយោជន៍ ស្រួលក្នុងការអានតែប៉ុណ្ណោះ តែដោយមានសំណូមពរពីបងប្អូន ព្រមទាំងគ្រួសារទាំងអស់ ដែលបានរួបរួមគ្នា បរិច្ចាគប្រាក់ដើម្បីបោះពុម្ពផងនោះ។ ខ្ញុំព្រះករុណានាងខ្ញុំ ក៏សម្រេចចិត្តបោះពុម្ព ដើម្បីបានចែកជាធម្មទាន ។

ហេតុនេះ បើមានការខុសឆ្គង ពុំគួរគប្បីយ៉ាងណា សូមករុណា មេត្តាអភ័យទោស ដោយក្តីអនុគ្រោះផងចុះ ហើយ

សូមអនុមោទនាយកនូវចំណែកនៃបុណ្យឲ្យបានជាប្រយោជន៍ រៀងៗព្រះអង្គ និង គ្រប់ៗគ្នា តាមសេចក្តីប្រាថ្នា ។

សូមឲ្យព្រះពុទ្ធសាសនា បានឋិតនៅអស់កាលយូរអង្វែងទៅហោង ។

**ដោយសេចក្តីជ្រះថ្លា ក្នុងបំណងល្អ !**

**ថ្ងៃ សៅរ៍ ១៥កើត ខែ ចេត្រ ព.ស.២៥៥៥**

**ខ្ញុំព្រះករុណា នាងខ្ញុំ វ៉ាង ស៊ីណា**

**ហៅ មុំ**

# ឧទ្ទិសកថា

ខ្ញុំព្រះករុណា នាងខ្ញុំសូមឧទ្ទិសនូវបុណ្យកុសលដែលកើតឡើងក្នុងកិច្ចជាធម្មទាននេះ ជូនចំពោះជីដូនជីតា ជូនចំពោះអ្នកម្តាយរបស់ខ្ញុំព្រះករុណានាងខ្ញុំ ឧបាសិកា **ម៉ុត យ៉ាត** និងជូនចំពោះបងប្រុស **វ៉ាង ណារី** ។

សូមគោរពជូនលោកឪពុក **មី វ៉ាង** និង មាតាបិតាក្មេក សូមគោរពជូនលោកគ្រូជាម្ចាស់ អគ្គបណ្ឌិត **ម៉ុត សារឿន** សូមគោរពជូនលោកព្រឹទ្ធាចារ្យទាំងអស់ ។

សូមគោរពជូន លោកបណ្ឌិត និងបណ្ឌិតធម្មាចារ្យទាំងអស់។

សូមគោរពជូនពុទ្ធបរិស័ទទាំងអស់ ព្រមទាំងជូនដល់សព្វសត្វ មនុស្ស ទេវតាទាំងអស់ សូមមានចិត្តសោមនស្សត្រេកអរអនុមោទនា សូមអនុមោទនាធម្មទាន ។

# មាតិកា

**ឈ្មោះអត្ថបទ** **ទំព័រ**

១-ឱវាទព្រះសាស្តា ................................................ ១

២-សុត្តន្តបិដកសំយុត្តនិកាយ .................................. ៨

៣-បិដកលេខ៥២ ទំព័រ៦០ ..................................... ១៣

៤-សុត្តន្តបិដក ខុទ្ទកនិកាយ .................................... ២៤

៥-ធម្មបទគាថា អប្បទាន វគ្គទី២ .............................. ២៧

៦-ធម្មបទគាថា ភិក្ខុវគ្គ ........................................... ៤១

៧-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន .......................... ៤៧

៨-មេត្តគូមាណវគ្គប្បញ្ញា ........................................ ៥៤

៩-អាយាចនវគ្គ .................................................... ៦៩

១០-ឥទប្បច្ចយតា ................................................. ៧២

១១-ជំនួយសតិភាគទី២ ......................................... ៧៥

# ១-ឱវាទព្រះសាស្តា

## បណ្តាំលោកគ្រូ

លោកគ្រូជាម្ចាស់បានសម្តែង ខ្ញុំព្រះករុណានាងខ្ញុំ បានស្តាប់មកថា ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានសម្រេចដល់សេចក្តីសុខ ដែលមិនអាស្រ័យកាមទៀតទេ ។ ព្រមជាមួយគ្នានោះ ព្រះអង្គ បានសម្តែងដាស់តឿនអ្នកប្រព្រឹត្តធម៌ឲ្យចាំទុកថា បើអរិយ-សាវ័ក បានឃើញច្បាស់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខ ច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំង-ឡាយមានច្រើនពេកក្រៃ ។ អរិយសាវ័កនោះឯង បានវៀរចាក កាមទាំងឡាយ វៀរចាកអកុសលទាំងឡាយហើយ តែមិនទាន់ បាននូវបីតិ និងសុខៈនោះទេ កាលបើដូច្នេះ អរិយសាវ័កនោះ នឹងឈ្មោះថា មិនវិលត្រឡប់មករកកាមទាំងឡាយនោះ មិន មែនឡើយ ។

ឈ្មោះថាកាមមាន កាមតណ្ហា គឺចំណង់ក្នុងកាម បាន ដល់ការចង់បាន ចង់យក និង សេពសោយ ។ កាមទាំងឡាយ មានឧបមាដូចជាលំពែង និង អណ្តោត ជាទីកាប់ចិញ្ច្រាំនូវខន្ធ ទាំងឡាយ ។

ខន្ធទាំងឡាយមាន ៥ គឺ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។ ព្រះសាស្តា ព្រះអង្គទ្រង់ត្រាស់ថា បុគ្គលឃើញ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលជារបស់មិនទៀង ថាមិនទៀង ការឃើញរបស់បុគ្គលនោះ ជាសម្មា-ទិដ្ឋិ ។ កាលដែលបុគ្គលបានឃើញត្រូវដូច្នេះ ក៏រមែងនឿយ-ណាយ ។ សម្មាទិដ្ឋិ គឺជាការយល់ត្រូវ តាមហេតុផលពិត យល់ត្រូវក្នុងសច្ចធម៌ ។ សម្មាទិដ្ឋិ យល់ត្រូវក្នុងជីវិតដែលមានបរមត្ថធម៌ ជាធម៌ដែលអាស្រ័យបច្ច័យកើតឡើង ហើយរលត់ទៅវិញ ។ ជីវិតរស់នៅមានតែចិត្តដឹងអារម្មណ៍ និង អារម្មណ៍របស់ចិត្តតៗគ្នា ។ នេះជាការកើតឡើងនៃសង្ខារធម៌សុទ្ធ និង ជាតំណនៃសង្ខារធម៌នោះ ។ អ្វីៗគ្រប់យ៉ាង ជាអារម្មណ៍របស់ចិត្ត ។ ចិត្តកើតឡើង ចិត្តរស់នៅ ចិត្តបែកធ្លាយ ។ ការរស់នៅជាប្រក្រតី គឺចិត្តដឹងអារម្មណ៍ បុគ្គលអ្នករស់នៅដទៃផ្សេងទៀតក្រៅពីចិត្តដឹងអារម្មណ៍ កើតហើយរលត់ទៅមិនមានទេ ។ ចិត្តគិតបានសាងប្រឌិតនូវលោក និងសាងគ្រប់រឿងរ៉ាវទាំងអស់ដូចក្នុងសុបិន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក កុំយករបស់ដទៃជាទីពឹងទីរឭកឡើយ ចូរយកធម៌ជាទីពឹង យកធម៌ជាទីរឭក កុំយករបស់ដទៃជាទីពឹងទីរឭកឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលបើយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយករបស់ដទៃជាទីរឭក យកធម៌ជាទីពឹង

យកធម៌ជាទីរឮកហើយ គប្បីពិចារណារកហេតុផលដោយយោបល់ថា សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត កើតមកអំពីអ្វី មានមកអំពីអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនសិក្សាក្នុងអរិយធម៌ មិនបានឃើញពួក សប្បុរស មិនឈ្លាសវៃក្នុងសប្បុរសធម៌ មិនសិក្សាក្នុងសប្បុរសធម៌ រមែងពិចារណាឃើញនូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ឃើញនូវខ្លួនថា មានក្នុង រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ លុះ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ នោះ របស់បុគ្គលនោះប្រែប្រួលវិបត្តិផ្សេងៗទៅ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងដល់បុគ្គលនោះ។

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់នូវសេចក្តីមិនទៀង សេចក្តីប្រែប្រួល សេចក្តីវិនាស និង សេចក្តីរលត់ទៅនៃ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ហើយឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី របស់ទាំងអស់នេះ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ភិក្ខុនោះក៏លះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោម-

នស្ស និង សេចក្ដីចង្អៀតចង្អល់ចិត្តចេញបាន កាលបើភិក្ខុនោះលះបង់សេចក្ដីសោកជាដើមទាំងនោះចេញហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងនៅជាសុខ ភិក្ខុអ្នកមានធម៌ ជាគ្រឿងនៅជាសុខ ហៅថា អ្នករំលត់កិលេស ដោយអង្គនៃវិបស្សនានោះៗ ។

ម្នាលភិក្ខុ អរិយសាវ័កជាអ្នកចេះដឹង បានឃើញនូវព្រះអរិយៈទាំងឡាយ អ្នកឈ្លាសវៃក្នុងអរិយធម៌ បានទូន្មានខ្លួនក្នុងសប្បុរសធម៌ ក៏រមែងមិនពិចារណាឃើញ រូប ថាជាខ្លួនខ្លះ។ មិនឃើញ វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួនខ្លះ។ អរិយសាវ័កនោះ ដឹងច្បាស់តាមពិតនូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលមិនទៀងថា មិនទៀង ជាទុក្ខ ជាអនត្តា។ ម្នាលភិក្ខុ អរិយសាវ័ក កាលដឹងច្បាស់យ៉ាងនេះ កាលឃើញច្បាស់យ៉ាងនេះ ទើបអស់អាសវៈក្នុងលំដាប់បាន ។

បិដកលេខ៣៣ ទំព័រ១៩៣-១៩៤ ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញតាមសេចក្ដីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញទេ នុ៎ះមិនមែនជាអាត្មាអញទេ នុ៎ះមិនមែនជាខ្លួនអាត្មាអញទេ ។ វេទនា ។

សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញតាមសេចក្តីពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះថា នុ៎ះមិនមែនរបស់អាត្មាអញទេ នុ៎ះមិនមែនជាអាត្មាអញទេ នុ៎ះមិនមែនជាខ្លួនអាត្មាអញទេ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយក្នុងរូបផង ក្នុងវេទនាផង ក្នុងសញ្ញាផង ក្នុងសង្ខារទាំងឡាយផង រមែងនឿយណាយក្នុងវិញ្ញាណផង ។ កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តរួចស្រឡះហើយ ញាណក៏ឡើងកើតថា អាត្មាអញរួចស្រឡះហើយ ។ ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ លំនៅរបស់សត្វទាំងប៉ុន្មាន ភពដ៏ប្រសើរទាំងប៉ុន្មាន មានតែពួកអរហន្តទេ ដែលជាបុគ្គលខ្ពង់ខ្ពស់ ប្រសើរបំផុតក្នុងលោក ។ ព្រះមានព្រះភាគ ត្រាស់សូត្រនេះចប់ហើយ លុះព្រះសុគតជាសាស្តា ត្រាស់សូត្រនេះចប់ហើយ ទើបទ្រង់ត្រាស់គាថានេះ តទៅទៀតថា ៖

(១៥៣) ពួកអរហន្តមានសេចក្តីសុខណាស់ ពួកអរហន្តទាំងនោះមិនមានតណ្ហាទេ អស្មិមានៈ លោកផ្តាច់បង់ហើយ បណ្តាញគឺមោហៈ លោកទម្លាយចោលហើយ ។ លោកមិនដល់នូវការញាប់ញ័រដោយតណ្ហា និង ទិដ្ឋិទេ ចិត្តរបស់អរហន្តទាំងនោះ មិនល្អក់ទេ អរហន្តទាំងនោះជាអ្នកប្រសើរ មិនមានអាសវៈ មិនជាប់នៅក្នុងលោក ។ លោកមានព្រះ-សទ្ធម្មទាំង៧[១] ជាអារម្មណ៍ព្រោះកំណត់ដឹងនូវខន្ធទាំង ៥ ។

(ទំព័រ១៩៥) ពួកសប្បុរសតែងសរសើរចំពោះ ពួកអរ-ហន្តជាបុត្រ ជាឱរសរបស់ព្រះពុទ្ធ។ ពួកអរហន្តបរិបូណ៌ ដោយកែវ គឺពោជ្ឈង្គទាំង ៧ប្រការ បានសិក្សាចំពោះសិក្ខាទាំង៣ មានព្យាយាមច្រើន បានលះបង់នូវភ័យ និងសេចក្តីខ្លាចដ៏ពន្លឹកហើយប្រព្រឹត្តនៅ ។ ពួកអរហន្តជាមហានាគប្រកបដោយអង្គជាអសេក្ខៈទាំង១០ មានចិត្តនឹងធឹង (ដោយឧបចារ និង អប្បនា ទាំងឡាយ) អរហន្តទាំងនោះប្រសើរបំផុតក្នុងលោក អរហន្តទាំងនោះមិនមានតណ្ហាទេ ។ ញាណរបស់ អសេក្ខ-បុគ្គលកើតឡើងហើយ នេះជាទីបំផុតនៃអត្តភាព ផលណារបស់មគ្គព្រហ្មចារ្យ លោកបានចាក់ឆ្លុះក្នុងផលនោះហើយ ។

(ទំព័រ១៩៦) ពួកអរហន្ត មិនញាប់ញ័រចំពោះមានៈ

---

(១)ព្រះសទ្ធម្មទាំង៧ បានដល់ សទ្ធា ហិរិ ឱត្តប្បៈ ពាហុសច្ចៈ វីរិយៈ ឧបដ្ឋិតស្សតិ និង បញ្ញា ។ អដ្ឋកថា ។

ផ្សេងៗ អរហន្តទាំងនោះមានចិត្តផុតស្រឡះចាកភពថ្មីទៀត បានសម្រេចអរហន្ត បានឈ្នះ(នូវកិលេសមានរាគៈជាដើម) ក្នុងលោកហើយ រមែងមិនញាប់ញ័រចំពោះមានះផ្សេងៗ ។ អរហន្តទាំងនោះ មិនមានសេចក្តីត្រេកអរចំពោះទេវលោក មនុស្សលោក និង អបាយលោកឡើយ អរហន្តទាំងនោះ បានចាក់ធ្លុះនូវអរិយសច្ចទាំង៤ ជាបុគ្គលប្រសើរបំផុតក្នុងលោក ហើយបន្លឺនូវសីហនាទ ។

ព្រះបរមសាស្តាទ្រង់តែងតែទូន្មានប្រៀនប្រដៅថា៖ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរព្យាយាម ខំប្រតិបត្តិតាមធម៌ តាមវិន័យ ដែលតថាគតបានបញ្ញត្តហើយ ចូរកុំប្រមាទ គប្បីជាអ្នកប្រកបដោយសេចក្តីពិចារណារឿយៗ ឲ្យឃើញទោសព្រោះ សេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទ ត្រូវមានស្មារតី មានសីលបរិសុទ្ធល្អ មានតម្រិះតម្កល់ស្មើល្អ ចូររក្សាចិត្តរបស់ខ្លួនរឿយៗចុះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកមិនប្រមាទ ហើយនៅក្នុងធម្មវិន័យនេះ ភិក្ខុនោះនឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខបានជាមិនខាន ។

**អត្តានំ ទមយន្តិ បណ្ឌិតា** បណ្ឌិតទាំងឡាយតែងទូន្មានខ្លួន **បមាទោ រក្ខតោ មលំ** សេចក្តីប្រមាទជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

# ២-សុត្តន្តបិដក សំយុត្តនិកាយ
# ខន្ធវារវគ្គ

### ខន្ធសំយុត្ត អន្តវគ្គ បិដកលេខ ៣៤ ទំព័រ ១+៧+៨

(១)-ក្រុងសាវត្ថី ។បេ។ ក្នុងទីនោះឯង ។បេ។ព្រះមាន-ព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អន្តៈ(ចំណែក) នេះ មាន ៤យ៉ាង ។ អន្តៈ ៤យ៉ាង តើដូចម្តេច ។ គឺ

១-អន្តៈ គឺ សកាយ

២-អន្តៈ គឺ ហេតុឲ្យកើតឡើងនៃសកាយ

៣-អន្តៈ គឺ សេចក្តីរលត់នៃសកាយ

៤-អន្តៈ គឺ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសកាយ ។

(២)-ម្នាលភិក្ខុទាំងឡាយ ចុះអន្តៈគឺសកាយតើដូចម្តេច។

គប្បីឆ្លើយថា ឧបាទានក្ខន្ធទាំង៥ ។ ឧបាទានក្ខន្ធទាំង៥ តើដូចម្តេច ។ គឺ

១-រូបូបាទានក្ខន្ធ = រូប +ឧបាទានក្ខន្ធ

២-វេទនូបាទានក្ខន្ធ = វេទនា+ឧបាទានក្ខន្ធ

៣-សញ្ញូបាទានក្ខន្ធ = សញ្ញា+ឧបាទានក្ខន្ធ

៤-សង្ខារូបាទានក្ខន្ធ = សង្ខារ+ឧបាទានក្ខន្ធ

៥-វិញ្ញាណូបាទានក្ខន្ធ = វិញ្ញាណ+ឧបាទានក្ខន្ធ

(៣)-ម្នាលភិក្ខុទាំងឡាយ ចុះអន្ត: គឺ ហេតុឲ្យកើតឡើងនៃសកាយ តើដូចម្តេច ។ តណ្ហាដែលតាក់តែងនូវភពថ្មី ប្រកបដោយសេចក្តីរីករាយ និង ត្រេកអរ មានសេចក្តីរីករាយក្នុងអារម្មណ៍នោះៗ ។ តណ្ហានោះ តើដូចម្តេច ។ គឺ

១-កាមតណ្ហា

២-ភវតណ្ហា

៣-វិភវតណ្ហា

ម្នាលភិក្ខុទាំងឡាយ នេះហៅថា អន្ត: គឺ ហេតុឲ្យកើតឡើងនៃសកាយ ។

(៤)-ម្នាលភិក្ខុទាំងឡាយ ចុះអន្ត: គឺ សេចក្តីរលត់នៃសកាយ តើដូចម្តេច ។ សេចក្តីវិនាស និង សេចក្តីរលត់មិនមានសេសសល់នៃតណ្ហានោះ កិរិយាលះបង់ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចចាកតណ្ហានោះ សេចក្តីមិនអាល័យតណ្ហានោះឯណា ។ ម្នាលភិក្ខុទាំងឡាយ នោះហៅថា អន្ត: គឺ សេចក្តីរលត់នៃសកាយ ។

(៥)-ម្នាលភិក្ខុទាំងឡាយ ចុះអន្តៈ គឺបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសកាយ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។ តើដូចម្តេចខ្លះ ។ គឺ សេចក្តីយល់ត្រូវ១ សេចក្តីត្រិះរិះត្រូវ១ ការនិយាយត្រូវ១ ការងារត្រូវ១ ការចិញ្ចឹមជីវិតត្រូវ១ ការព្យាយាមត្រូវ១ សេចក្តីរលឹកត្រូវ១ ការតម្កល់ចិត្តត្រូវ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អន្តៈ គឺបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់នៃសកាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាអន្តៈ(ចំណែក)ទាំង ៤យ៉ាង ។

(៦)-ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវទុក្ខផង នូវហេតុឲ្យកើតឡើងនៃទុក្ខផង នូវសេចក្តីរលត់នៃទុក្ខផង នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃទុក្ខផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់ចុះ ។

(៧)-ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខ តើដូចម្តេច ។ គប្បីឆ្លើយថា៖ ឧបាទានក្ខន្ធទាំង ៥ គឺ ជាទុក្ខ ។ នេះហៅថា ទុក្ខ ។

(៨)-ម្នាលភិក្ខុទាំងឡាយ ចុះហេតុឲ្យកើតឡើងនៃទុក្ខ តើដូចម្តេច ។ តណ្ហាណា ដែលតាក់តែងនូវភពថ្មី ប្រកបដោយសេចក្តីរីករាយ និង សេចក្តីត្រេកអរ មានសេចក្តីរីករាយ ក្នុងអារម្មណ៍នោះៗ ។ តណ្ហានោះ តើដូចម្តេច គឺ កាមតណ្ហា១ ភវតណ្ហា១ វិភវតណ្ហា១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា

ហេតុ ឲ្យកើតឡើងនៃទុក្ខ ។

(៩)-ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីរលត់នៃទុក្ខតើដូចម្ដេច ។ សេចក្ដីវិនាស និង សេចក្ដីរលត់មិនមានសល់នៃតណ្ហានោះ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចចាកតណ្ហានោះ សេចក្ដីមិនអាល័យក្នុងតណ្ហានោះ ឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្ដីរលត់នៃទុក្ខ ។

(១០)-ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់សេចក្ដីរលត់ទុក្ខ តើដូចម្ដេច ។ គឺ អរិយមគ្គប្រកបដោយអង្គ ៨ប្រការ នោះឯង ។

(១៦)-ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវធម៌ដែលបុគ្គលគប្បីកំណត់ដឹងផង នូវបុគ្គលអ្នកកំណត់ដឹងផង អ្នកទាំងឡាយ ចូរស្ដាប់នូវសេចក្ដីនោះចុះ ។

(១៧)-ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលបុគ្គលគប្បីកំណត់ដឹង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ រូបជាធម៌ដែលបុគ្គលគប្បីកំណត់ដឹង ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ គឺជាធម៌ដែលបុគ្គលគប្បីកំណត់ដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលបុគ្គលគប្បីកំណត់ដឹង ។

(១៨)-ម្នាលភិក្ខុទាំងឡាយ ចុះការកំណត់ដឹង តើដូច-

ម្ដេច ការអស់ទៅនៃ រាគៈ ការអស់ទៅនៃ ទោសៈ ការអស់ទៅនៃមោហៈ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការកំណត់ដឹង។

(១៩)-ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកកំណត់ដឹង តើ ដូចម្ដេច ។ គប្បីឆ្លើយថា ព្រះអរហន្ត ។ គឺ លោកមានអាយុណា មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលអ្នកកំណត់ដឹង ។

**ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា៖**

**សទ្ទហានោ អរហតំ ធម្មំ និព្វាន បត្តិយា**

**សុស្សូសំ លភតេ បញ្ញំ អប្បមត្តោ វិចក្ខណោ** ។

បុគ្គលជឿធម៌របស់ព្រះអរហន្តទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីដល់ព្រះនិព្វាន បុគ្គលមានប្រាជ្ញាពិចារណា មិនប្រមាទ កាលស្ដាប់ដោយសេចក្ដីគោរព រមែងបាននូវប្រាជ្ញា ។

# ៣-បិដកលេខ៥២ ទំព័រ ៦០

ការត្រឡប់បានអត្តភាពជាមនុស្ស ជាការបានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ការស្តាប់ធម៌ របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយបានដោយកម្រ ។ ការមិនធ្វើនូវបាបទាំងពួង ការញ៉ាំងកុសលឲ្យកើតឡើង ការធ្វើចិត្តឲ្យផូរផង់ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

បិដកលេខ៣៣ ទំព័រ ៣២៥ ព្រះពុទ្ធមានផៅពង្សដូចព្រះអាទិត្យ ទ្រង់សម្តែងហើយថា រូបដូចជាដុំនៃពពុះទឹក វេទនាដូចជាក្រពេញទឹក សញ្ញាដូចជាថ្ងៃបណ្តើរកូន សង្ខារ ដូចជាដើមចេក វិញ្ញាណដូចជាកលមាយា ។ បុគ្គលក្រឡេក មើលដោយប្រការណា១ រមែងពិចារណាដោយឧបាយ ដោយប្រការនោះ១ បុគ្គលណាឃើញនូវខន្ធបញ្ចកៈនោះដោយឧបាយ ខន្ធបញ្ចកៈនោះ ជារបស់សោះសូន្យទទេតែងប្រាកដ (ដល់បុគ្គលនោះ) ។ ការលះបង់នូវធម៌ទាំង៣ ដែលព្រះមាន-ព្រះភាគ មានបញ្ញាដូចជាផែនដី ទ្រង់ប្រារព្ធនូវកាយនេះហើយសម្តែង អ្នកទាំងឡាយ ចូរឃើញនូវរូបដែលគេចោលហើយ ។ អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែងលះបង់នូវកាយនេះ ដែលជាចំណីនៃសត្វដទៃ មិនមានចេតនា ក្នុងកាលណាហើយ កាយដែលគេចោលហើយ រមែងដេកលើផែនដី ក្នុង

កាលនោះ ។ ធម៌ជាតំណ[១] នេះ ប្រាកដដូច្នេះឯង កិច្ចកល នេះជាគ្រឿងប្រលោមនូវជនពាល ខន្ធនេះអ្នកប្រាជ្ញពោល ហើយ ថាជាពេជ្ឈឃាដមួយ ឯខ្លឹមវម៉ែងមិនមានក្នុងខន្ធនេះ ឡើយ ។ ភិក្ខុមានព្យាយាម តឹងតែង មានសេចក្ដីដឹងខ្លួន មាន សតិដ៏មាំ គប្បីពិចារណានូវ ខន្ធយ៉ាងនេះទាំងយប់ទាំងថ្ងៃ ។ គប្បីលះបង់នូវសំយោជនៈទាំងពួង គប្បីធ្វើនូវទីពឹងសម្រាប់ ខ្លួន កាលបើប្រាថ្នានូវព្រះនិព្វាន ដែលមិនមានចុតិ គប្បីប្រព្រឹត្ត រួសរាន់ ដូចជាបុគ្គលមាន ភ្លើងឆេះក្បាល ។

(ទំព័រ៣៣៩) ម្នាលភិក្ខុទាំងឡាយ សង្សារនេះមាន ទីបំផុតគេ មិនអាចដឹងបាន គឺទីបំផុតខាងដើម របស់សត្វទាំង ឡាយ ដែលមានអវិជ្ជាជាគ្រឿងបិទបាំង មានតណ្ហាជាចំណង អន្ទោលទៅ មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាន សម័យដែលត្រូវមហាសមុទ្រ រីងស្ងួតមិនមានសេសសល់ នៅ ។ មានសម័យដែលស្ដេចភ្នំ ឈ្មោះ**សិនេរុ** ត្រូវភ្លើងឆេះ វិនាសទៅ មិនមានសេសសល់នៅ ។ មានសម័យដែលមហា ប្រឹថពី ត្រូវភ្លើងឆេះវិនាសទៅ មិនមានសេសសល់នៅ ។ ម្នាល ភិក្ខុទាំងឡាយ ពួកសត្វ ដែលមានអវិជ្ជាជាគ្រឿងបិទបាំង មាន តណ្ហាជាចំណងអន្ទោលទៅ ត្រាច់រង្គាត់ទៅ តថាគតមិនពោល ថាធ្វើនូវទីបំផុតនៃទុក្ខ បានឡើយ ។

---

(១) ធម៌ជាបវេណី ។

(២៥៧) ម្នាលភិក្ខុទាំងឡាយ ដូចជាឆ្កែដែលគេចង ដោយដងដោយ ចងភ្ជាប់នឹងបង្គោលសសរដ៏រឹងមាំ ឆ្កែនោះ រមែងស្ទុះក្រឡឹង ដើរក្រឡឹងបង្គោល ឬសសរនោះឯង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនជាអ្នកមិនចេះដឹង មិនឃើញពួកព្រះអរិយៈ ។បេ។ មិនបានសិក្សាក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ឃើញនូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ ។ បុថុជ្ជននោះ រមែងស្ទុះក្រឡឹង ដើរក្រឡឹងនូវរូបដដែលៗ ។ ក្រឡឹងនូវវេទនាដដែលៗ នូវសញ្ញា សង្ខារ វិញ្ញាណ ដដែលៗ ។ ទើបតថាគតពោលថាមិនរួចចាករូប មិនរួចចាក វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនរួចចាក ជាតិ ជរា មរណៈ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ លំបាកចិត្ត និង សេចក្ដីចង្អៀតចង្អល់ចិត្តទាំងឡាយ មិនរួចចាកទុក្ខឡើយ ។

*ជាការពិតណាស់ ការត្រឡប់បានអត្តភាពជាមនុស្ស ជាការបានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ព្រោះហេតុនេះ មនុស្សយើងដែលបានកើតមកជាមនុស្ស បានទាន់ព្រះពុទ្ធសាសនា គប្បីខំព្យាយាមស្វែងរកការចេះដឹង ដើម្បីបានចម្រើនផ្លូវចិត្ត មិនគួរបណ្ដោយខ្លួនឲ្យនៅតែល្ងង់នោះ នៅឡើយ ។

*សេចក្តីល្ងង់គឺជាអវិជ្ជា អវិជ្ជាគឺជាសត្រូវរបស់បុគ្គលដែលមានសេចក្តីល្ងង់ ។

*បិដកលេខ៦៧ ទំព័រ១៣ អជិតមាណពទូលសួរព្រះ-មានព្រះភាគថា៖ បពិត្រព្រះអង្គដ៏ចម្រើន លោកត្រូវអ្វីបិទបាំង លោកមិនភ្លឺស្វាង ព្រោះហេតុអ្វី សូមព្រះអង្គទ្រង់ត្រាស់ប្រាប់នូវធម៌អ្វី ជាគ្រឿងលាបលោកនេះ អ្វីជាភ័យធំរបស់លោកនោះ។

(៥៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា៖ ម្នាលអជិតៈ លោកត្រូវអវិជ្ជាបិទបាំង លោកមិនភ្លឺងស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ (និងសេចក្តីប្រហែស) តថាគតពោលនូវសេចក្តីប្រាថ្នា ជាគ្រឿងលាប ទុក្ខជាភ័យធំរបស់លោកនោះ ។

*ពាក្យថាលោកគឺ និរយលោក តិរច្ឆានលោក បិត្តិ-វិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកខាងមុខ ព្រហ្មលោក នេះហៅថា លោក ។

*ពាក្យថា អវិជ្ជា បានន័យថា សេចក្តីមិនដឹងក្នុងទុក្ខ សេចក្តីមិនដឹងក្នុងតណ្ហា ជាហេតុឲ្យកើតទុក្ខ សេចក្តីមិនដឹងក្នុងកិរិយារលត់ទុក្ខ សេចក្តីមិនដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម និង

ទីបំផុតខាងចុង ។ សេចក្តីមិនដឹងក្នុងធម៌ដែលកើតឡើងហើយ អាស្រ័យធម៌ នេះជាបច្ច័យ ភាពជាពាល ភាពមិនមានសម្បជញ្ញៈ សេចក្តីវង្វេង មោហៈ អកុសលមូលណា មានសភាពយ៉ាងនេះ នេះហៅថា អវិជ្ជា ។

(៦៥) អជិតមាណពមានអាយុ ក្រាបបង្គំទូលសួរដូច្នេះថា៖ ខ្សែទាំងឡាយ រមែងហូរទៅក្នុងទីទាំងពួង អ្វីជាគ្រឿងរារាំងនូវខ្សែទាំងឡាយ សូមព្រះអង្គទ្រង់សម្តែងធម៌ជាគ្រឿងបិទនូវខ្សែទាំងឡាយ បុគ្គលបិទខ្សែទាំងឡាយបានដោយអ្វី ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិតៈ ខ្សែទាំងឡាយណាក្នុងលោក សតិជាគ្រឿងបិទខ្សែទាំងនោះ តថាគតពោលនូវការបិទខ្សែទាំងឡាយ ខ្សែទាំងនោះបុគ្គលបិទបានដោយបញ្ញា ។

*ពាក្យថាខ្សែទាំងឡាយ បានដល់ខ្សែគឺ តណ្ហា ខ្សែគឺកិលេស ខ្សែគឺ ទុច្ចរិត ខ្សែគឺ អវិជ្ជា ។ ពាក្យថា ក្នុងទីទាំងពួង គឺក្នុងអាយតនៈទាំងពួង ។ ពាក្យថា ហូរទៅ ប្រព្រឹត្តទៅ អំពីភ្នែកទៅកាន់រូប អំពីត្រចៀកទៅកាន់សំឡេង អំពីច្រមុះទៅកាន់ក្លិន អំពីអណ្តាតទៅកាន់រស អំពីកាយទៅកាន់ផ្សព្វ ហូរទៅ ប្រព្រឹត្តទៅអំពីចិត្ត ទៅកាន់ធម្មារម្មណ៍ ។

*ពាក្យថាបញ្ញា គឺការដឹងច្បាស់ ភាពនៃការឈ្លាសវៃ

ប្រាជ្ញាសម្រាប់ឃើញច្បាស់ ឥន្ទ្រិយគឺបញ្ញា កម្លាំងគឺបញ្ញា សេចក្តីមិនវង្វេង សេចក្តីយល់ត្រូវ ។ ពាក្យថាសតិ បានដល់ សេចក្តីរលឹក សេចក្តីរលឹករឿយៗ សេចក្តីរលឹកត្រូវ ។

*អវិជ្ជាគឺជាសត្រូវរបស់បុគ្គលល្ងង់ បុគ្គលដែលមានសេចក្តីល្ងង់ សូម្បីមាននូវសទ្ធាហើយ ក៏ជាការទន់ខ្សោយពោល គឺដូចជាមានការបូជា ចំពោះព្រះរតនត្រ័យ ក៏មិនមាននូវកម្លាំងមាំមួនឡើយ ដូច្នេះទើបពុទ្ធបរិស័ទ គប្បីស្វែងយល់ពីខ្លឹមសារធម៌ ដែលជាឧបការៈនាំឲ្យកើតបញ្ញា ។ បើពុទ្ធបរិស័ទបានយល់ដឹងពីខ្លឹមសារធម៌ ដោយសេចក្តីព្យាយាម ដោយសេចក្តីឆ្លាត ឈ្លាស ជាពុទ្ធបរិស័ទដល់ព្រមដោយសទ្ធា និងបញ្ញាហើយ ការបូជាដល់ព្រះរតនត្រ័យ រមែងសម្រេចផលប្រមាណមិនបានឡើយ សូម្បីក្នុងពេលដែលកំពុងបូជានេះ សភាពនៃចិត្តក៏បរិសុទ្ធ ព្រោះប្រកបដោយ បីតិ បស្សទ្ធិ និងសមាធិ ដែលជាខ្លឹមសារនៃសេចក្តីសុខ ។

ក្នុងធម្មបទពុទ្ធវគ្គ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែងថា៖ អ្នកណាៗក៏មិនអាចរាប់នូវបុណ្យ របស់អ្នកដែលបូជាដល់បុគ្គលដែលគួរបូជា គឺព្រះពុទ្ធ និង សាវ័ក របស់ព្រះពុទ្ធទាំង-ឡាយផង ជាអ្នកកន្លងនូវបបញ្ចធម៌ (ធម៌ជាគ្រឿងយឺតយូរបានដល់ តណ្ហា មានះ ទិដ្ឋិ)បានឡើយ សូម្បីបុគ្គលដែលគួរបូជាទាំង នោះ ជាអ្នកមិនមានភ័យអំពីទីណា បានបរិនិព្វានទៅ

ហើយក៏ដោយ ក៏នៅតែមិនមានអ្នកណាៗអាចរាប់បុណ្យរបស់អ្នកបូជានោះបានឡើយ ។ ដូច្នេះទើបពុទ្ធបរិស័ទគប្បីជាអ្នកបានសិក្សាព្រះធម៌ មានការសិក្សាតាមរយៈនៃការអានព្រះត្រៃ-បិដក អានសៀវភៅ និង តាមរយៈនៃការស្តាប់ ដែលជាបច្ច័យឲ្យចម្រើនទៅដោយ សតិ បញ្ញា ឲ្យកើតការយល់ដឹងក្នុងព្រះពុទ្ធសាសនាផង និង បានយល់ដឹងក្នុងរឿងពិតទាំងឡាយរបស់ជីវិតផង ។ លោកគ្រូជាម្ចាស់ បានសម្តែងថា មនុស្សយើងគប្បីសាងនូវសេចក្តីល្អឲ្យបានច្រើន គឺត្រូវតែមាននូវសេចក្តីព្យាយាមក្នុងការសិក្សាអំពីព្រះពុទ្ធសាសនា ព្រោះព្រះពុទ្ធសាសនា ជាសាសនាចង្អុលបង្ហាញពីហេតុ និង ណែនាំអប់រំឲ្យសត្វលោកដើរនៅក្នុងផ្លូវត្រូវ គឺផ្លូវនៃសេចក្តីសុខច្រើនដែលសត្វលោកខ្លួនឯងប្រាថ្នាចង់បាន ព្រះពុទ្ធសាសនា គឺជាផែនទីនៃជីវិតសត្វលោក ឯការប្រព្រឹត្តរបស់សត្វលោក គឺជាការដើរផ្លូវ ។

ព្រះពុទ្ធសាសនា បានបង្ហាញប្រាប់ផ្លូវនៃសេចក្តីសុខមាន ៣ប្រការ គឺ ការមិនធ្វើនូវអំពើអាក្រក់ទាំងពួង១ ការបំពេញនូវសេចក្តីល្អ១ និង ការសម្អាតចិត្តរបស់ខ្លួនឲ្យបានស្អាតផូរផង់១ ។

*ការមិនធ្វើនូវអំពើអាក្រក់ទាំងពួង សំខាន់បំផុតគឺការមិនបៀតបៀនអ្នកដទៃ ដើម្បីការមិនបៀតបៀនអ្នកដទៃមនុស្ស

យើងត្រូវតែអប់រំចម្រើននូវធម៌មេត្តាឲ្យមានក្នុងចិត្ត ដែលគេតែងហៅថា (មនុស្សមានធម៌ក្នុងខ្លួន) តាមពិតចិត្តដែលមានមេត្តា ជាចិត្តមាននូវសេចក្តីសុខ មនុស្សយើងត្រូវចេះស្វែងរកសេចក្តីសុខពីចិត្តរបស់ខ្លួនឯងផង ព្រោះកាលណាបើមាននូវសេចក្តីសុខក្នុងចិត្តហើយ រមែងមានសេចក្តីសុខស្ងប់ជាពិតប្រាកដ ។ សេចក្តីសុខដែលបានពីចិត្តរបស់ខ្លួនឯង គឺសេចក្តីសុខដែលកើតក្នុងចិត្តរបស់ខ្លួនឯង នៅជាក់ក្នុងចិត្តជាប្រចាំដោយមិនបានអាស្រ័យរបស់ខាងក្រៅ ដូចជាលាភសក្ការៈ កិត្តិយស កេរ្តិ៍ឈ្មោះ ការគោរពរាប់អាន និង ពាក្យសរសើរជាដើមឡើយ ។ សេចក្តីសុខប្រភេទបែបនេះ ជាសេចក្តីសុខមានភាពស្រស់ថ្លា ។ សេចក្តីសុខ គឺអនវជ្ជសុខ សុខកើតអំពីការងារប្រាសចាកទោស រីករាយក្នុងចិត្តត្បិតខ្លួន មានការប្រព្រឹត្តសុចរិតទាំង៣ មានកាយសុចរិត វចីសុចរិត មនោសុចរិត មានការចិញ្ចឹមជីវិតដោយប្រពៃ មិនធ្វើជាទាសៈនៃថៅកែបាប (បានសេចក្តីថា) មិនបម្រើចិត្តបាបរបស់ខ្លួនឯងឡើយ ។

**(នត្ថិ សន្តិ បរំសុខំ សេចក្តីសុខអ្វីស្មើនឹងសេចក្តីស្ងប់មិនមាន)**

*ការបំពេញនូវសេចក្តីល្អ គប្បីជាបុគ្គលដែលតម្កល់ខ្លួននៅក្នុងធម៌របស់សប្បុរស ជាបុគ្គលចេះទូន្មានខ្លួន ធ្វើការងារប្រពៃ ជាការងាររួចផុតចាកបាបកម្ម និង ពៀរវេរា មានសេចក្តីព្យាយាមក្នុងការបំពេញតួនាទីឲ្យបានល្អ ព្យាយាមក្នុង

ការរក្សាខ្លួនដោយស្មារតី គឺរក្សាឲ្យបានល្អទៅដោយគុណធម៌ សុចរិតធម៌ ព្រហ្មចរិយធម៌ និង សុជីវធម៌ ។

*ការសម្អាតចិត្តឲ្យស្អាត អាស្រ័យដោយបញ្ញា គឺការយល់ដឹងអំពីការពិតនៃជីវិត បញ្ញាធ្វើកិច្ចកម្ចាត់បង់នូវគ្រឿងសៅហ្មងរបស់ចិត្ត ដូច្នេះក្នុងជីវិតប្រចាំថ្ងៃ គប្បីអប់រំចម្រើនបញ្ញា ។ ការសិក្សាអំពីសេចក្តីពិតនៃជីវិត ដោយយោនិសោ-មនសិការ ជាហេតុនាំឲ្យចម្រើននូវបញ្ញា យោនិសោមនសិការ គឺឆ្លាតក្នុងការពិចារណា បានដល់ការពិចារណារកហេតុផលនៃអ្វីៗដែលបានកើតឡើង ព្រោះអ្វីៗដែលបានកើតឡើងក្នុងជីវិត សុទ្ធតែត្រឹមត្រូវពិតទៅតាមហេតុ ។

បុគ្គលដែលមិនបានសិក្សា អំពីការពិតនៃជីវិត រមែងញាប់ញ័រ ដូចត្រីនៅក្នុងទីដែលមានទឹកតិច សត្វលោកផ្ញើសេចក្តីសុខរបស់ខ្លួនតែនឹងរបស់ខាងក្រៅ ម្ល៉ោះហើយចិត្តរបស់សត្វលោកត្រូវសៅហ្មងជានិច្ចដោយ(**ឆន្ទរាគៈ**) ទាំងដែលសៅ-ហ្មង ព្រោះការមិនបានឃើញទោសរបស់**ឆន្ទរាគៈ**ទៀតផង ។ បុគ្គលដែលបានសិក្សាអំពីសេចក្តីពិតនៃជីវិត បានកំណត់ដឹងចំពោះរបស់ដែលមិនទៀង ថាមិនទៀង រមែងនាំឲ្យឃើញទោសនៃ **ឆន្ទរាគៈ** ជាហេតុនៃសេចក្តីទុក្ខ និង នាំឲ្យមានភាពស្អាតផូរផង់ មានភាពភ្លឺស្វាង ។ ការពិតជីវិតជាច្បាប់ហេតុផល ផលរមែងប្រព្រឹត្តទៅតាមហេតុ ដូច្នេះកិច្ចរបស់បញ្ញា ក្រៅអំពី

ធ្វើការសម្អាតចិត្តឲ្យស្អាតផូរផង់នោះ បញ្ញានៅមានកិច្ចសាងហេតុនៃសេចក្តីសុខក្នុងជីវិតបានយ៉ាងសម្បូណ៌ទៀតផង ព្រោះបញ្ញាបានយល់អំពីហេតុផលនៃធម្មជាតិ ។

ពុទ្ធបរិស័ទ ដែលបានយល់ដឹងអំពីជីវិត គឺពុទ្ធបរិស័ទមានការចម្រើនទៅដោយគុណធម៌ ព្រោះគុណធម៌ គឺ មេត្តាករុណាក្តី សេចក្តីសន្តោសក្តី សេចក្តីព្យាយាមក្តី សីលក្តី សមាធិក្តី ខន្តីសេចក្តីអត់ធន់ក្តី ជាដើមនេះ រមែងកើតឡើងចម្រើនក្នុងចិត្ត គឺដោយអាស្រ័យ ការយល់ដឹងអំពីសេចក្តីពិតរបស់ជីវិត ។ ការសាងគុណធម៌ឲ្យចម្រើនក្នុងចិត្ត នេះគឺជាប្រយោជន៍ដ៏មានខ្លឹមសារក្នុងជីវិតរបស់មនុស្សគ្រប់រូប ។ ពុទ្ធ-បរិស័ទដែលមាន សេចក្តីព្យាយាម សិក្សាដោយល្អ ពិចារណាដោយល្អ បដិបត្តិដោយល្អ បានអប់រំខ្លួនរាល់ថ្ងៃ មានចិត្តមាំមួនអធិដ្ឋានតាំងចិត្តពិតប្រាកដ បដិសេធនូវអារម្មណ៍ដែលនាំឲ្យភ្លើតភ្លើនផ្សេងៗ រមែងបានទៅជាព្រះអរិយបុគ្គល អស់ទុក្ខអស់កង្វល់ជាពិតប្រាកដ និង ឆ្លងនូវសង្សារវដ្តបានពុំខានឡើយ ។ ព្រះបរមសាស្តា ព្រះអង្គទ្រង់ប្រារព្ធភិក្ខុមួយអង្គដែលចង់សឹក ។

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**

**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ**

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រ ក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នាក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

# ៤-សុត្តន្តបិដក ខុទ្ទកនិកាយ

## ធម្មបទគាថា បិដកលេខ ៥២

សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

(១១)-ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោស[១] ប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដាន ជើងគោដែលកំពុងអូសទៅ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លា[២] ហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

(ទំព័រ២៣) ជនទាំងឡាយ ដែលយល់ឃើញក្នុងធម៌មានខ្លឹមថា ជាធម៌មិនមានខ្លឹមផង ជាអ្នកមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ ។ ជនទាំង-

---

(១)ធម៌ជាទោសឬជាឧបកិលេសនៃចិត្តមានអភិជ្ឈាជាដើម ដែលចូលមកធ្វើចិត្តឲ្យរីករវ ។
(២)ជ្រះថ្លាដោយគុណមានអនភិជ្ឈាជាដើម ។ អដ្ឋកថា។

ឡាយដែលយល់ឃើញនូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង យល់ឃើញនូវធម៌គ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជាអ្នកមានតម្រិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹម ។

*ផ្ទះដែលប្រក់ខ្ទីខ្ទាហើយ តំណក់ទឹកភ្លៀងរមែងលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ដោតយ៉ាងនោះឯង ។

(ទំព័រ២៨) ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀងរមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។ បុគ្គលអ្នកធ្វើបាប រមែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយក្នុងលោកនេះ១ ក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងសោកស្តាយក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ១ រីករាយក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។ បុគ្គលអ្នកធ្វើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ១ ក្តៅក្រហាយក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងក្តៅក្រហាយ ដោយគិតឃើញថា បាបអាត្មាអញបានធ្វើហើយ លុះធ្វើមរណកាលទៅ

កាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំងពីរ គឺត្រេកអរក្នុងលោកនេះ១ ត្រេកអរក្នុងលោកខាងមុខ១ បុគ្គលនោះរមែងត្រេកអរ ដោយគិតឃើញថា បុណ្យអាត្មាអញបានធ្វើទុកហើយ លុះធ្វើមរណកាលទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

(ទំព័រ២៥) បើនរជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីច្រើន តែជាអ្នកប្រមាទមិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចជាអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដែលជាម្ចាស់គោរួចហើយ (ខ្លួនឯងជាអ្នករក្សាក៏មិនបានបរិភោគនូវបញ្ចគោរស)ដូច្នោះឯង ។

# ៥.ធម្មបទគាថា អប្បមាទ វគ្គទី២

(១២)- សេចក្តីមិនប្រមាទ[១] ជាផ្លូវនៃសេចក្តីមិនស្លាប់[២] សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយដែលមិនប្រមាទហើយឈ្មោះថា មិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ[៣] ជននោះ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា (ទើបឋិតនៅ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាទីគោចរ[៤] នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញាតែងប៉ះពាល់នូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតិដ៏ប្រសើរបំផុត ។ យស[៥] តែងចម្រើនកុះករដល់បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណា រួចហើយទើបធ្វើជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។ អ្នកប្រាជ្ញ

(១)បានដល់ការប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះស្មារតី ដែលបានតាំងប្រុងជានិច្ច។ (២)ពាក្យថាមិនស្លាប់នេះ ជាឈ្មោះព្រះនិព្វាន ព្រោះព្រះនិព្វានមិនមានចាស់ មិនមានស្លាប់។(៣) បានដល់ការមិនប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះនៃការលះបង់ស្មារតី។(៤)ពោធិបក្ខិយធម៌៣៧និងលោក-កុត្តរធម៌៩ហៅថាគោចរនៃអរិយៈ។(៥)ភាពជាធំ.ភោគសម្បត្តិ.សេចក្តីរាប់អាន.កិត្តិសព្ទដ៏ពីរោះ .គុណទាំងនេះរួមហៅថាយស។

គប្បីសាងកោះ គឺអរហត្តផល ជាកោះដែលជំនន់ គឺកិលេស ជន់ពន្លិចមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយការទូន្មានឥន្ទ្រិយផង ។ ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗនូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទដូចទ្រព្យយ៉ាងប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗនូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗនូវសេចក្តីរីករាយ ត្រេកអរក្នុងកាមឡើយ ត្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្តីសុខ ដ៏ទូលាយ ។

(ទំព័រ២៧) កាលណាបណ្ឌិតបន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ កាលនុ៎ះ លោកនឹងឡើងកាន់ប្រាសាទ គឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ធីរជនតែងឃើញពួកជនពាល(អ្នកមិនចេះដឹង) ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលឋិតនៅលើផែនដី ដូច្នោះឯង ។

បណ្ឌិត មានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រលឹកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែប

នោះ ដូចសេះលឿន ដែលទៅចោលនូវសេះ ដែលមានកម្លាំងទន់ទាប ដូច្នោះឯង ។

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុតជាងទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ ហើយតែងតែត្មះតិះដៀលនូវសេចក្តីប្រមាទ សព្វៗកាល ។

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ តែងដុតចោលសំយោជនៈ ទាំងតូច ទាំងធំ ដូចភ្លើងឆេះ (រាលនូវកំទេចទាំងតូចទាំងធំ) ដូច្នេះឯង ។

(ទំព័រ២៨) ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

(១៣)- ចិត្តវគ្គទី៣ អ្នកប្រាជ្ញតែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះ ដែលបុគ្គលលើកឡើងចាកអាល័យគឺកាមគុណ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីទៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើង ចាកទីនៅគឺទឹក បោះទៅលើគោក ដូច្នោះឯង ។

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតិរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នាក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច (ព្រោះថា) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

(ទំព័រ២៩) អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នាក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប៤ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្ដីជ្រះថ្លាអណ្ដែតទៅ ។ ភ័យរមែងមិនមានដល់បុគ្គលអ្នកមានចិត្ត មិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យ និងបាបលះចោលហើយ ភ្ញាក់រឭកជានិច្ច ។ បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធគឺបញ្ញា គប្បីរក្សា

ទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកដំអក់នៅ(ក្នុងធម៌នោះ) ឡើយ ។

(ទំព័រ៣០) ឱហ្ន៎! មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅប្រាស គេយកទៅចោលផុតហើយ មុខជានឹងដេកស្តូកស្តឹងលើផែនដី ដូចជាអង្កត់អុស រកប្រយោជន៍គ្មាន ។

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏ បុគ្គលមានពៀរណាមួយដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែង ជាងសេចក្តីវិនាសនោះទៅទៀត ។

មាតាបិតាក៏មិនគប្បីធ្វើនូវហេតុនោះបាន ឬជនទាំង-ឡាយដទៃជាញាតិ ក៏មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះ ។

(១៤)- បុប្ផវគ្គទី៤ អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និង យមលោកគឺអបាយភូមិ៤ និង មនុស្ស-លោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចនាយមាលាការ ដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះឯង ។

(ទំព័រ៣១) ព្រះសេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និង យមលោកគឺអបាយភូមិ៤ និង មនុស្ស-លោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គល នឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគត សម្តែងប្រពៃហើយ ដូចនាយមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះឯង។

ភិក្ខុ (ឬបុគ្គល) កាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថា មានសភាពដូចជាថ្ងៃបណ្តើរកូន គប្បីកាត់នូវផ្កាជាប្រធាននៃមារគឺវដ្តៈ ៣ ទៅកាន់ស្ថាន ជាទីដែលមច្ចុរាជមើលមិនឃើញ ។

មច្ចុគឺសេចក្តីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នុ៎ះឯង ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុក កំពុងដេកលក់ទៅ ដូច្នោះឯង ។

អ្នកធ្វើទីបំផុតគឺមរណៈ តែងក្រុងសត្វ ដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនុ៎ះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌ និង ក្លិនឲ្យវិនាសទេ គឺក្រេបយកតែរសហើយហើរទៅ យ៉ាងណាមិញ អ្នក

ប្រាជ្ញគប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

(ទំព័រ៣២) ពាក្យចាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិន គួរធ្វើទុកក្នុងចិត្តទេ ព្រោះកិច្ចដែលធ្វើហើយ និង មិនទាន់ធ្វើហើយរបស់ជនដទៃ (នោះមិនមែនជាមុខការរបស់ ខ្លួន) បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យពិចារណាតែ កិច្ចការទាំងឡាយរបស់ខ្លួនដែលបានធ្វើរួចហើយ និង នៅមិន ទាន់បានធ្វើតែម្យ៉ាងប៉ុណ្ណោះ ។

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌(ល្អ) តែគ្មានក្លិន (ក្រអូប) (រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្ដេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាម ដូច្នោះ ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្ដេចមិញ វាចាជាសុភា-សិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះ ឯង ។

នាយមាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរ នៃផ្កាផ្សេងៗគ្នាឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វ កើតមកហើយ គួរធ្វើឲ្យច្រើន យ៉ាងនោះ ។

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹម ចន្ទន៍ក្ដី ក្លិនខ្លឹមក្រស្នាក្ដី ក្លិនផ្កាម្លិះក្ដី ក៏ផ្សាយទៅច្រាសខ្យល់

មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស។ ក្លិននៃសីលជាគុណជាតិប្រសើរបំផុត ជាងគន្ធជាតទាំងនេះគឺ ខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះ ។

(ទំព័រ៣៣) ក្លិនក្រស្នា និង ក្លិនចន្ទន៍ណា ក្លិននេះក្រអូប មានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះទើបក្រអូបលើសលប់ ក្រអូបផ្សាយទៅក្នុងទេវលោក និង មនុស្សលោកបាន ។

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបនូវផ្លូវរបស់លោកអ្នកមានសីលបរិបូណ៌ ជាអ្នកនៅដោយសេចក្តីមិនប្រមាទ ជាអ្នករួចស្រឡះ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

ផ្កាឈូក ទុកជាដាក់លើគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ បណ្តាជន ដែលដូចជាគំនរសំរាម សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងកន្លងផុតបុថុជ្ជនទាំងឡាយដែលងងឹតល្ងង់ ដោយប្រាជ្ញា (របស់ខ្លួន) ដូច្នោះឯង ។

(ពាលវគ្គទំព័រ៣៤) រាត្រីវែង ចំពោះតែ(អ្នកដេកមិនលក់) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង

ចំពោះតែបុគ្គលពាល(អ្នកមិនចេះដឹង) ដែលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

(ទំព័រ៣៥) បុគ្គលពាល ទោះបីចូលទៅអង្គុយជិតអ្នកប្រាជ្ញសូម្បីអស់មួយជីវិត ក៏ឥតបានដឹងរសធម៌អ្វី ឲ្យច្បាស់-លាស់ឡើយ ដូចវែកដែលមិនដឹងរសសម្ល ។

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច ក៏រមែងបានដឹង បានយល់រសនៃព្រះធម៌ ដោយឆាប់រហ័ស ប្រៀបដូចអណ្តាតដឹងនូវរសសម្ល ដូច្នោះឯង ។

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវតែងធ្វើកម្មលាមក ដែលជាអំពើមានផលក្តៅក្រហាយ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់ទៅដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ ។

(បណ្ឌិតវគ្គទំព័រ៣៧) បុគ្គល គួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ ។ បុគ្គលគួរគប់ (សេពគប់) អ្នកប្រាជ្ញបែបនោះ (ព្រោះថា) បើបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមាន

ទោសដ៏លាមកឡើយ ។

(ទំព័រ៣៨) បណ្ឌិត គួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជន ទាំងឡាយចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃពួកជនអសប្បុរសឡើយ ។

បណ្ឌិត ដែលមានសេចក្ដីឆ្អែតក្នុងធម៌ មានចិត្តជ្រះ-ថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ដែលព្រះ-អរិយៈប្រកាសទុកហើយ គ្រប់ពេល ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ(ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ (ឲ្យស្មើ ឲ្យរលោង) ឯបណ្ឌិតទាំងឡាយ តែងតែទូន្មានខ្លួន ដូច្នោះឯង ។

**យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ**
**ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។**

អន្លង់ទឹកដែលជ្រៅ ហើយថ្លាស្អាត រមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ កាលបើបានស្ដាប់ព្រះធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់សួន (ជាចិត្តស្អាតបរិសុទ្ធ) យ៉ាងនោះឯង ។

(បាបវគ្គទំព័រ៤៧) បុគ្គល មិនគួរមើលងាយបាបថា

មានប្រមាណតិច និង មិនឲ្យផលដូច្នោះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ (ម្តង១តំណក់) យ៉ាងណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ អាចពេញបានដោយបាប ក៏យ៉ាងនោះដែរ ។

(ទំព័រ៤៨) បុគ្គល គួរខ្លាច គួរជៀសវាងនូវបាបទាំងឡាយ ឲ្យដូចពាណិជ ដែលមានទ្រព្យច្រើន តែមានគ្នាតិច ជៀសវាងផ្លូវដែលគួរខ្លាច ឬដូចជាបុរសប្រាថ្នារស់នៅ ជៀសវាងថ្នាំពិស ដូច្នោះដែរ ។

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសមិនអាចជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅបាន យ៉ាងណា បាបរមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

បុគ្គលណា ជាអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ ឬទៅកាន់ចន្លោះភ្នំទាំងឡាយ ក៏មិនអាចរួចចាកបាបកម្ម បានឡើយ ព្រោះប្រទេសលើ ផែនដីដែលបុគ្គលឋិតនៅហើយ គប្បីអាចរួចចាកបាបកម្មបាន នោះមិនដែលមានទេ ។

(ជរាវគ្គទំព័រ៥៣) អត្តភាពណា មិនទៀងទាត់ ឋិតថេរ អ្នកចូលមើលអត្តភាព(នោះ) ដែលកុសលាកុសលកម្ម ធ្វើ

វិចិត្រហើយ ជាកាយពាសពេញដោយដំបៅ ដែលឆ្អឹងបីរយកំណាត់ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះរបស់ជន ច្រើនគ្នា ។

រូប តែងចាស់គ្រាំគ្រា ជាទីសំណាក់នៃរោគ ជារបស់ពុកផុយ រាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញព្រោះថា ជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល តើសេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ) ព្រោះហេតុតែឃើញនូវឆ្អឹងទាំង-ឡាយនោះ ។

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តីលុបគុណ ប្រជុំចុះក្នុងសរីរៈណា (សរីរៈនោះ) ដែលកុសលាកុសលកម្មធ្វើហើយ ឲ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់ និង ឈាម ។

រាជរថទាំងឡាយដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា តែធម៌របស់សប្បុរសទាំងឡាយមិនដល់នូវសេចក្តីគ្រាំគ្រា (ដូច្នោះទេ) សប្បុរសទាំងឡាយតែងនិយាយឲ្យពួកសប្បុរសផងគ្នា បានដឹង ។

(ទំព័រ៥៤)

**អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ**
**មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ។**

បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់ (ឥតអំពើ) ដូចគោ បម្រើសាច់របស់វាតែងចម្រើនឡើង តែប្រាជ្ញារបស់វា មិនចម្រើនឡើយ ។

**អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។**

កាលតថាគតមិនទាន់បានជួបប្រទះនូវ(ពោធិញាណរវល់តែ) ស្វះស្វែងរកជាងផ្ទះគឺតណ្ហា ជាអ្នកធ្វើផ្ទះគឺអត្តភាពក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។

**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា។**

នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញអ្នកហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀតមិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់

ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគតកំចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមាន សង្ខារប្រាសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហា ទាំងឡាយហើយ ។

(ពុទ្ធវគ្គទំព័រ៦១) ការស្កប់ស្កល់ ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះកហាបណៈ (ដែលធ្លាក់ចុះ) ដូចទឹកភ្លៀងទេ កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន អ្នក-ប្រាជ្ញដឹងច្បាស់យ៉ាងនេះហើយ លោកមិនបានត្រេកអរក្នុងកាមទាំងឡាយ សូម្បីជាទិព្វឡើយ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធរមែងជាអ្នកត្រេកអរក្នុងធម៌ ជាគ្រឿងអស់តណ្ហា ប៉ុណ្ណោះ ។

មនុស្សទាំងឡាយច្រើនអ្នក ត្រូវភ័យ(ដែលជាសេចក្តីទុក្ខ)គំរាមហើយ តែងយកភ្នំ អារាម និង រុក្ខចេតិយជាទីពឹង តែទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលណាដែលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។

(ទំព័រ៦២) លុះត្រាតែបុគ្គលយក ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ទីរលឹក ឃើញច្បាស់នូវអរិយសច្ចទាំង៤ គឺ ទុក្ខសច្ច១ ទុក្ខសមុទយសច្ច១ និរោធសច្ច កន្លងទុក្ខ១ អរិយ-មគ្គប្រកបដោយអង្គ៨ ជាដំណើរទៅកាន់ព្រះនិព្វាន ដែលជាទីរម្ងាប់ទុក្ខ១ ដោយប្រាជ្ញដ៏ប្រពៃ នេះឯងជាទីពឹងដ៏ឧត្តម

បុគ្គលណា អាស្រ័យនូវទីពឹងបែបនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

# ៦ ធម្មបទគាថា ភិក្ខុវគ្គ

## បិដកលេខ ៥២ ទំព័រ ៩៨

(៣៥)-ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្ដាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការប្រព្រឹត្តសង្រួមទាំងអស់ប្រពៃ ភិក្ខុ (បុគ្គល) សង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

បុគ្គលណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយហៅជននោះថាភិក្ខុ។

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សម្ដែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះទើបឈ្មោះថា ពីរោះ ។

ភិក្ខុ មានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែងមិនសាបសូន្យចាក ព្រះ-សទ្ធម្មឡើយ ។

(ទំព័រ៩៩) បុគ្គលណា មិនមានសេចក្ដីប្រកាន់ក្នុង

នាម និង រូប ថាជារបស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោកស្តាយ ព្រោះនាម និង រូប ដែលមិនមាន បុគ្គលនោះ ឯង តថាគតហៅថា ភិក្ខុ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ម្នាលភិក្ខុ ចូរអ្នកស្តារទូកគឺអត្តភាពនេះ ទូកដែលអ្នក ស្តារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈ និង ទោសៈបាន ហើយ អំពីនោះ នឹងអាចដល់នូវ ព្រះនិព្វាន ។

(ទំព័រ១០១) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជម្រុះរាគៈ និង ទោសៈចេញ ដូចម្លិះជម្រុះផ្កាម្លិះដែលស្វិត ទាំងឡាយហើយ ដូច្នោះឯង ។

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសៈក្នុង លោក ខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់ ។

អ្នកទាំងឡាយ ចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរ ពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ បុគ្គលណាដែលមានស្មារតី រក្សាខ្លួនដោយល្អប្រពៃហើយ នឹងនៅជាសុខ ។

ជាការពិតណាស់ ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររវាំងខ្លួន ដូចពាណិជរវាំងសេះដ៏ល្អ ។

(ទំព័រ១០៣) ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ហើយពេញដោយយសសមណព្រាហ្មណ៍អ្នកមានឈាន រមែងរុងរឿង ឯព្រះសម្ពុទ្ធរមែងរុងរឿងដោយតេជះរហូត គឺរមែងរុងរឿងទាំងយប់ទាំងថ្ងៃ។

(ទំព័រ១១៦-១១៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់ ១សប្តាហ៍ ។ បន្ទាប់មកទ្រង់ចេញ អំពីសមាធិនោះ ហើយទ្រង់រំពឹងក្នុងព្រះហឫ-ទ័យ ចំពោះបដិច្ចសមុប្បាទធម៌ ជាអនុលោម និងបដិលោមអស់រាត្រីបឋមយាម ដោយប្រពៃថា កាលបើបច្ច័យនេះមានផលនេះក៏មាន ផលនេះរមែងកើតឡើង ព្រោះការកើតឡើងនៃបច្ច័យនេះ កាលបើបច្ច័យនេះមិនមាន ផលនេះក៏មិនមានផលនេះរលត់ទៅ ព្រោះរលត់ទៅនៃបច្ច័យនេះ គឺសង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ

សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈ ជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទាន ជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរា មរណៈកើត មានព្រម ព្រោះជាតិជាបច្ច័យ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ក៏រមែងកើតមាន ។ ការកើតឡើងនៃ កងទុក្ខទាំង អស់នុ៎ះ រមែងមានយ៉ាងនេះឯង ។ ការរលត់ទៅនៃសង្ខារ ព្រោះរលត់អវិជ្ជាឥតមានសេសសល់ ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់សង្ខារ ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណ ការរលត់ទៅនៃ សឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ ទៅនៃផស្សៈ ព្រោះ រលត់សឡាយតនៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈ ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនា ការរលត់ទៅនៃ ឧបាទាន ព្រោះរលត់តណ្ហា ការរលត់ទៅនៃ ភព ព្រោះរលត់នៃភព ព្រោះរលត់ឧបាទាន ការរលត់ទៅនៃ ជាតិ ព្រោះរលត់ភព ជរា មរណៈរលត់ព្រម ព្រោះរលត់ជាតិ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ក៏រមែងរលត់ ទៅ ។ សេចក្តីរលត់នៃ កងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាង នេះឯង ។ លុះព្រះមានព្រះភាគបរមសាស្តា ទ្រង់ជ្រាបច្បាស់ សេចក្តីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា៖

**យទា ហវេ បាតុភវន្តិ ធម្មា**

**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស**

**វិធូបយំ តិដ្ឋតិ មារសេនំ**

**សុរិយោវ ឱភាសយមន្តលិក្ខន្តិ ។**

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ ដុតបង់នូវកិលេសក្នុងកាលណា ព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារ ព្រមទាំងសេនាមារ ហើយឋិតនៅក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើង ធ្វើអាកាសឲ្យរុងរឿងដោយរស្មីរបស់ខ្លួន កម្ចាត់បង់នូវភាពងងឹត ហើយឋិតនៅដូច្នោះឯង ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថាៈ បុរសអ្នកកម្ចាត់បង់នូវអកុសលវិតក្ក ដោយសេចក្តីខ្មាសបាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូចសេះល្អខ្លាចរំពាត់ បុរសនេះរកបានដោយក្រក្នុងលោក ។ សេះល្អ ដែលនាយសារថីទូន្មានដោយរំពាត់ តក់ស្លុតយ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្តីតក់ស្លុតយ៉ាងនោះចុះ បើអ្នកទាំងឡាយប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិន័យផង ជាអ្នកមានវិជ្ជា និង ចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំហើយនោះ អ្នកនឹង អាចលះបង់ទុក្ខ ដែលមានប្រមាណច្រើននេះបាន ជាមិន

ខាន ។

(ទណ្ឌវគ្គទំព័រ៥១) ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាៈ

**អលង្កតោ ចេបិ សមំ ចរេយ្យ**

**សន្តោ ទន្តោ និយតោ ព្រហ្មចារី**

**សព្វេសុ ភូតេសុ និធាយ ទណ្ឌំ**

**សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។**

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអម្ពរ) តែជាអ្នកប្រព្រឹត្តស្មើ ជាអ្នកស្ងប់រម្ងាប់ ជាអ្នកទូន្មាននូវ(ឥន្ទ្រិយ) ជាបុគ្គលទៀង(ចំពោះមគ្គផល) ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះហៅថា ព្រាហ្មណ៍ក៏បាន ហៅថាសមណៈក៏បាន ហៅថា ភិក្ខុក៏បាន ។

# ៧-សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន

## ទំព័រ២២៦

(១១១)-ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិក សេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចេញអំពីទីសំងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមាន-ព្រះភាគ លុះចូលទៅដល់ហើយ (ទំព័រ២២៧) ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មាន-អាយុអង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមាតារបស់ព្រះមានព្រះភាគ មានជន្មាយុតិចណាស់ កាលព្រះមាន-ព្រះភាគប្រសូតបាន ៧ថ្ងៃ ព្រះមាតារបស់ព្រះអង្គ ទ្រង់ក៏សោយព្រះវិលាល័យ ទៅកើតក្នុងទេវនិកាយ ឯស្ថានតុសិត ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ដំណើរនុ៎ះ មែនហើយ ម្នាលអានន្ទ ដំណើរនុ៎ះមែនហើយ ម្នាលអានន្ទ ព្រោះថា ព្រះមាតារបស់ ព្រះពោធិសត្វទាំងឡាយ តែងមានព្រះជន្មា-យុតិច កាលព្រះពោធិសត្វទាំងឡាយ ទ្រង់ប្រសូតបាន ៧ថ្ងៃ ព្រះមាតារបស់ ព្រះពោធិសត្វទាំងឡាយ ក៏សោយព្រះវិលា-ល័យ ហើយទៅកើតក្នុងទេវនិកាយ ឯស្ថានតុសិត(ជាធម្មតា)។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះ ហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា៖

ពួកសត្វណាមួយ ដែលកើតហើយក្តី នឹងកើត(ក្នុងអនាគត)ក្តី ពួកសត្វទាំងអស់នោះ នឹងលះបង់នូវរាងកាយទៅកាន់(បរលោក)ដូចគ្នា បណ្ឌិតអ្នកឈ្លាស ដឹងច្បាស់នូវសេចក្តីសាបសូន្យទាំងអស់នោះហើយ គួរជាអ្នកមានព្យាយាម ប្រព្រឹត្តព្រហ្មចរិយធម៌ ។

(ទំព័រ៣០៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ បានពន្យល់ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាច្រើនប្រការ។ លំដាប់នោះ ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ដែលបានព្រះ-សារីបុត្តដ៏មានអាយុ ពន្យល់ហើយដោយធម្មីកថា ជាច្រើនប្រការ ចិត្តរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ដែលព្រះសារីបុត្តដ៏មានអាយុបានពន្យល់ហើយ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា៖

(ទំព័រ៣០៨) បុគ្គលដែលរួចស្រឡះចាកសង្ខារទាំងពួង ក្នុងចំណែកខាងលើគឺ រូបធាតុ និង អរូបធាតុ ក្នុងចំណែកខាងក្រោម គឺកាមធាតុ មិនឃើញថា នេះជាអាត្មាអញ លុះរួចស្រឡះយ៉ាងនេះហើយ ក៏បានឆ្លងអន្លង់(ទាំង៤) ដែលខ្លួនមិនធ្លាប់ឆ្លង មិនប្រព្រឹត្តទៅ ដើម្បីភពថ្មីទៀតឡើយ ។

(១៤៨)-សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុសម្គាល់ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុថាជាសេក្ខៈក៏ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ជាច្រើនប្រការ មានប្រមាណដ៏ក្រៃលែង ។ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា៖

(ទំព័រ៣០៩) បុគ្គល កាលបើបានកាត់ផ្តាច់វដ្តៈ បានដល់ព្រះនិព្វាន ដែលមិនមានតណ្ហា ស្ទឹងរីងស្ងួត មិនហូរទៅយ៉ាងណា កិលេសវដ្តៈ ដែលបុគ្គលកាត់ផ្តាច់ហើយ រមែងមិនប្រព្រឹត្តទៅ (ក៏យ៉ាងនោះដែរ) នេះជាទីបំផុតនៃទុក្ខ ។

(ទំព័រ៣៤៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើប្រាសាទរបស់មិគារមាតាក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ចៅស្រីដែលជាទីស្រឡាញ់ពេញចិត្ត របស់នាងវិសាខាមិគារមាតា ធ្វើមរណ-

ភាព ។ គ្រានោះ វិសាខាមិគារមាតា មានសំពត់សើម មានសក់សើម ចូលទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃត្រង់ លុះចូលទៅដល់ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវិសាខា ចុះនាងមកពីណា មានសំពត់សើម សក់សើម ចូលមកក្នុងទីនេះទាំងថ្ងៃត្រង់ ។ បពិត្រព្រះអង្គដ៏ចម្រើន ចៅស្រីជាទីស្រឡាញ់ ពេញចិត្តរបស់ខ្ញុំព្រះអង្គធ្វើមរណភាព ព្រោះហេតុនោះ ទើបបានជាខ្ញុំព្រះអង្គមាន សំពត់សើម សក់សើម ចូលមកក្នុងទីនេះទាំងថ្ងៃត្រង់ ។ ម្នាលវិសាខា តើមនុស្សក្នុងក្រុងសាវត្ថី មានចំនួនប៉ុន្មាន នាងចង់បានកូន និង ចៅចំនួនប៉ុណ្ណោះឬ ។ បពិត្រព្រះមាន-ព្រះភាគដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថីមានចំនួនប៉ុន្មាន ខ្ញុំព្រះអង្គក៏ចង់បានកូន និង ចៅចំនួនប៉ុណ្ណោះដែរ ។ ម្នាលវិសាខា ចុះមនុស្សទាំងឡាយ ក្នុងក្រុងសាវត្ថីជាច្រើននាក់ តែងតែធ្វើមរណភាពជារៀងរាល់ថ្ងៃ មានប៉ុន្មាននាក់ ។ បពិត្រព្រះអង្គដ៏ចម្រើនមនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពជារៀងរាល់ថ្ងៃមាន ១០នាក់ខ្លះ ៩នាក់ខ្លះ ៨នាក់ខ្លះ ៧នាក់ខ្លះ ៦នាក់ខ្លះ ៥នាក់ខ្លះ ៤នាក់ខ្លះ ៣នាក់ខ្លះ ២នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណភាពរាល់ៗថ្ងៃ តែម្នាក់ខ្លះក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សក្នុងក្រុង-សាវត្ថី តែងតែធ្វើមរណភាពមិនដែលស្វាត់ទេ ។ ម្នាលវិសាខា

នាងសម្គាល់ហេតុនោះដូចម្ដេច ចុះនាងជាអ្នកមានសំពត់សើម សក់សើម ក្នុងកាលម្ដងៗដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះមិនមែនដូច្នោះទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះ-អង្គ ល្មមត្រឹមតែកូន និង ចៅច្រើនប៉ុណ្ណោះ ។ ម្នាលវិសាខា បុគ្គលណា (ទំព័រ៣៤៩) មានវត្ថុជាទីស្រឡាញ់ ១០០ បុគ្គលនោះ មានសេចក្ដីទុក្ខ១០០ បុគ្គលណាមានវត្ថុជាទីស្រឡាញ់ ៩០ បុគ្គលនោះមានសេចក្ដីទុក្ខ ៩០ បុគ្គលណាមានវត្ថុជាទីស្រឡាញ់៥០ បុគ្គលនោះមានសេចក្ដីទុក្ខ ៥០ ។ល។

(ទំព័រ៣៥០) បុគ្គលណា មានវត្ថុជាទីស្រឡាញ់១ បុគ្គលនោះ មានសេចក្ដីទុក្ខ១ បុគ្គលណាមិនមានវត្ថុជាទីស្រឡាញ់ បុគ្គលនោះ ក៏មិនមានសេចក្ដីទុក្ខសោះដែរ ។ តថាគតទើបពោលថា បុគ្គលទាំងនោះ ជាអ្នកមិនមានសោក ជាបុគ្គលប្រាសចាកធូលី គឺកិលេស ជាអ្នកមិនមានសេចក្ដីចង្អៀតចង្អល់ ។ លុះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាន នេះ ក្នុងវេលានោះថា៖

សេចក្ដីសោកក្ដី សេចក្ដីខ្សឹកខ្សួលក្ដី ណាមួយ ឬសេចក្ដីទុក្ខជាច្រើនយ៉ាងក្នុងលោក ធម៌ទាំងនុ៎ះ រមែងកើតឡើង ព្រោះអាស្រ័យសត្វ និង សង្ខារជាទីស្រឡាញ់ កាលបើមិនមាន សត្វ និង សង្ខារ ជាទីស្រឡាញ់ធម៌ទាំងនុ៎ះ ក៏រមែងមិនមាន ។ ព្រោះហេតុនោះឯង បុគ្គលណាមិនមានសត្វ និង សង្ខារជាទី

ស្រឡាញ់ក្នុងលោកណាមួយទេ បុគ្គលនោះ ទើបមានសេចក្ដីសុខ ប្រាសចាកសេចក្ដីសោក ព្រោះថា បុគ្គលប្រាថ្នាសេចក្ដីមិនសោក និង ការប្រាសចាកធូលីគឺកិលេស មិនគប្បីធ្វើសត្វ និង សង្ខារ ឲ្យជាទីស្រឡាញ់ ក្នុងលោកណាមួយឡើយ ។

ក្នុងធម្មបទគាថា បិយវគ្គ ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា បុគ្គល កាលប្រកបខ្លួនទុក ក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួន ក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយកាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់ បុគ្គលអ្នកប្រកបតាមខ្លួន ។ អ្នកទាំងឡាយ ចូរកុំគប់រកសត្វ និង សង្ខារទាំង-ឡាយដែលជាទីស្រឡាញ់ និង មិនជាទីស្រឡាញ់ ក្នុងកាលណាៗឡើយ ព្រោះថា ការមិនជួបប្រសព្វសត្វ និង សង្ខារជាទីស្រឡាញ់ ការជួបប្រសព្វសត្វ និង សង្ខារ មិនជាទីស្រឡាញ់ក្ដីសុទ្ធតែជាហេតុដែលនាំមកនូវសេចក្ដីទុក្ខ ។ ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វ និង សង្ខារ ឲ្យជាទីស្រឡាញ់ឡើយ ព្រោះការព្រាត់ប្រាសចាកសត្វ និង សង្ខារ ជាទីស្រឡាញ់ ជាសភាពអាក្រក់ ការស្រឡាញ់ និង ការស្អប់ មិនមានដល់ពួកជនណា កិលេសគ្រឿងចាក់ស្រេះទាំងឡាយ តែងមិនមានដល់ពួកជននោះ ។

សេចក្ដីសោកកើតអំពីសេចក្ដីស្រឡាញ់ ភ័យកើតអំពីសេចក្ដីស្រឡាញ់ កាលបើរួចស្រឡះចាក សេចក្ដីស្រឡាញ់

ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើចិត្តរួចស្រឡះចាកតម្រេកហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើចិត្តរួចស្រឡះចាកកាមហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

# ៨-មេត្តគូមាណវកប្បញ្ហា

## បិដកលេខ ៦៧ ទំព័រ១២២

(មេត្តគូមានអាយុ ទូលសួរព្រះមានព្រះភាគដូច្នេះថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ សូមព្រះអង្គ ត្រាស់ប្រាប់នូវសេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ខ្ញុំព្រះអង្គ សម្គាល់ឃើញថា ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំហើយ សេចក្តីទុក្ខទាំងឡាយណាមួយ មានជាច្រើនប្រការក្នុងលោក តើសេចក្តីទុក្ខទាំងនោះ កើតមកអំពីណាហ្ន៎ ។

(១៤៧)-ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលមេត្តគូ អ្នកសួរហេតុជាដែនផ្តើមកើតនៃសេចក្តីទុក្ខនឹងតថាគត តថាគតដឹងយ៉ាងណា នឹងប្រាប់ហេតុជាដែនផ្តើមកើតនៃទុក្ខនោះដល់អ្នកយ៉ាងនោះ ម្នាលមេត្តគូ សេចក្តីទុក្ខទាំងឡាយជាច្រើនប្រការក្នុងលោក សេចក្តីទុក្ខ(ទាំងនោះ) ផ្តើមកើតព្រោះឧបធិ ជានិទាន។

ពាក្យថាទុក្ខ បានដល់ ជាតិទុក្ខ ព្យាធិទុក្ខ ជរាទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ ។ ការត្រូវព្យាធិគ្របសង្កត់ ការត្រូវមរណៈកម្ចាត់បង់ ការឥតទីពឹងទាំងនេះលោកហៅថា ទុក្ខ ។ ទុក្ខទាំងនេះមាន ទុក្ខទាំងនេះ

ផ្តើមកើតឡើង ព្រោះឧបធិជានិទាន ព្រោះឧបធិជាហេតុ ព្រោះឧបធិជាបច្ច័យ ហេតុនោះ(ទ្រង់ត្រាស់ថា) សេចក្តីទុក្ខទាំងនោះផ្តើមកើតឡើង ព្រោះឧបធិជានិទាន ។

ពាក្យថា ឧបធិ បានដល់ ឧបធិ១០ គឺ តណ្ហូបធិ ទិដ្ឋូបធិ កិលេសូបធិ កម្មូបធិ ទុច្ចរិតូបធិ អាហារូបធិ បដិឃូបធិ ឧបាទិន្នធាតុ៤ ជាឧបធិ អាយតនៈខាងក្នុង៦ ជាឧបធិ វិញ្ញាណកាយ៦ ជាឧបធិ សូម្បីទុក្ខទាំងអស់ ក៏ឈ្មោះថាឧបធិ ដោយសេចក្តីថា ទុក្ខទាំងអស់នេះ លោកហៅថា ឧបធិ១០ ។

(ទំព័រ១៣០) ព្រះមានព្រះភាគបរមសាស្តា ទ្រង់ត្រាស់ថា៖ បុគ្គលមិនចេះ តែងធ្វើនូវឧបធិឲ្យកើតឡើង បុគ្គលល្ងង់ខ្លៅនោះ រមែងបានទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ ជាអ្នកពិចារណាឃើញនូវជាតិជាដែនផ្តើមកើតនៃទុក្ខ មិនគប្បីធ្វើនូវឧបធិឡើយ ។

(១៥៧) មេត្តគូទូលថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំបានទូលសួរសេចក្តីណា ព្រះអង្គបានត្រាស់ប្រាប់សេចក្តីនោះដល់យើងខ្ញុំ យើងខ្ញុំសូមទូលសួរសេចក្តីឯទៀត ចំពោះព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ អ្នកប្រាជ្ញទាំងឡាយអាចឆ្លងឱឃៈផង ជាតិ ជរា ផង សោកៈ និង បរិទេវៈផង ដោយប្រការដូចម្តេចហ្ន៎ សូមព្រះអង្គជាមុនី ដោះស្រាយនូវ

ឧបាយ ជាគ្រឿងឆ្លងនោះដល់យើងខ្ញុំ ព្រោះព្រះអង្គជ្រាបច្បាស់នូវធម៌នោះហើយ ។

ពាក្យថា ឱឃៈ បានដល់ ឱឃៈគឺកាម ឱឃៈគឺភព ឱឃៈគឺទិដ្ឋិ ឱឃៈគឺអវិជ្ជា ។

(ទំព័រ១៨២) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមេត្តគូ តថាគតនឹងសម្ដែងធម៌ដល់អ្នក ជាធម៌ដែលជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ជាធម៌ដែលបុគ្គលមានសតិ ដឹងហើយប្រព្រឹត្ត គប្បីឆ្លងវិសត្តិកាតណ្ហាក្នុងលោកបាន។

(១៦៧) មេត្តគូទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គស្វែងរកគុណដ៏ធំ មានសតិ ទ្រង់ជ្រាបនូវធម៌ណា ជាធម៌ដ៏ឧត្តមហើយប្រព្រឹត្ត គប្បីឆ្លងវិសត្តិកាតណ្ហាក្នុងលោកបាន ចំណែកខ្ញុំព្រះអង្គត្រេកអរចំពោះធម៌នោះ ។

(១៦៨) អធិប្បាយពាក្យថា ព្រះអង្គស្វែងរកគុណដ៏ធំ ជាធម៌ដ៏ឧត្តម សំណួរត្រង់ពាក្យថា (ស្វែងរកគុណដ៏ធំ) ចុះឈ្មោះថា ស្វែងរកគុណដ៏ធំ តើដោយអត្ថដូចម្ដេច ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះព្រះមានព្រះភាគ ទ្រង់ស្វែងរក ស្វះ-ស្វែងរកនូវ សីលក្ខន្ធដ៏ធំ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់ស្វែងរក ស្វះស្វែងរកនូវ សមាធិខន្ធដ៏ធំ បញ្ញាខន្ធដ៏ធំ វិមុត្តិខន្ធដ៏ធំ វិមុត្តិញ្ញាណទស្សនក្ខន្ធដ៏ធំ ។ មួយទៀត ឈ្មោះថា

ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការទម្លាយនូវគំនរនៃងងឹតដ៏ធំ ។ ឈ្មោះថា រកគុណដ៏ធំ ព្រោះទ្រង់បំបែកនូវវិបល្លាសដ៏ធំ ព្រោះទ្រង់បានដកនូវសរគឺតណ្ហាដ៏ធំ ព្រោះទ្រង់បានទម្លាយនូវឃ្នាបគឺទិដ្ឋិដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការទម្លាយចុះនូវទង់គឺមានះដ៏ធំ ។ ព្រោះទ្រង់បានរម្ងាប់នូវអភិសង្ខារដ៏ធំ ។ ឈ្មោះថាស្វែង រកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែងរកនូវការរើឡើងនូវឱឃៈដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការដាក់ចុះនូវភារៈដ៏ធំ ព្រោះទ្រង់ផ្ដាច់បង់នូវសង្សារវដ្តដ៏ធំ ព្រោះទ្រង់ រំលត់នូវកម្ដៅដ៏ធំ ព្រោះទ្រង់រម្ងាប់នូវសេចក្ដីរោលរាលដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែងរក នូវការលើកឡើងនូវទង់គឺធម៌ដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវសតិប្បដ្ឋានដ៏ធំ សម្មប្បធានដ៏ធំ ឥទ្ធិបាទដ៏ធំ ឥន្ទ្រិយដ៏ធំ ពលៈដ៏ធំ ពោជ្ឈង្គៈដ៏ធំ មគ្គដ៏ប្រសើរប្រកបដោយអង្គ៨ដ៏ធំ អមតនិព្វានមានអត្ថដ៏ក្រៃលែងដ៏ធំ ។ មួយទៀតឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះពួកសត្វមានស័ក្តិដ៏ធំ រក ស្វែង ស្វះស្វែងថា ព្រះពុទ្ធគង់ក្នុងទីណា ព្រះមានព្រះភាគគង់ក្នុងទីណា ព្រះអង្គជាទេវតាប្រសើរជាងទេវតាគង់ក្នុងទីណា ព្រះអង្គជានរៈដ៏ក្លៀវក្លាគង់ក្នុងទីណា ។

ពាក្យថា (ធម៌ដ៏ឧត្តម) បានសេចក្តីថា អមតនិព្វាន លោកហៅថា ធម៌ដ៏ឧត្តម បានខាងការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាក តម្រេក ការរលត់ និព្វាន ។

(ទំព័រ១៥០) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាល មេត្តគូ បើអ្នកដឹងច្បាស់នូវធម្មជាតិណាមួយ ទាំងខាងលើ ខាងក្រោម និង ទទឹង គឺកណ្តាលហើយ អ្នកចូរបន្ទោបង់នូវ សេចក្តីត្រេកត្រអាលផង សេចក្តីប្រកាន់ផង វិញ្ញាណផង ក្នុង ធម៌ទាំងឡាយ នុ៎ះចេញ ទើបមិនឋិតនៅក្នុងភព ។

(១៧៦) ភិក្ខុមានការនៅយ៉ាងនេះ មានសតិ អ្នកមិន ប្រហែស លះបង់សេចក្តីប្រកាន់ ហើយប្រព្រឹត្ត ជាអ្នកចេះដឹង គប្បីលះបង់នូវទុក្ខគឺ ជាតិ ជរា សោកៈ និង បរិទេវៈ ក្នុងលោក នេះបាន។

(១៨០) មេត្តគូ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ-ព្រះអង្គត្រេកអរចំពោះព្រះវាចានុ៎ះ របស់ព្រះមហេសី បពិត្រ ព្រះគោតម ព្រះនិព្វានជាគុណជាតិ មិនមានឧបធិ ព្រះអង្គ បានសម្តែង ព្រះមានព្រះភាគ លះទុក្ខបានដោយពិត ព្រោះ ធម៌នុ៎ះ ព្រះអង្គ ទ្រង់ជ្រាបច្បាស់ហើយ ។

(១៨៥) បពិត្រព្រះមុនី ព្រះអង្គបានទូន្មានជនណា

ដោយត្រឹមត្រូវ ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ព្រោះហេតុនោះ ខ្ញុំព្រះអង្គចូលមក នមស្ការចំពោះព្រះអង្គ ជាព្រះពុទ្ធនាគ សូមព្រះមានព្រះភាគទូន្មានខ្ញុំព្រះអង្គ ដោយត្រឹម-ត្រូវចុះ ។

(១៩០) ព្រះមានព្រះភាគ ទ្រង់តបថា បុគ្គលគប្បីដឹងច្បាស់នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ ជាអ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព ព្រាហ្មណ៍នោះ ឈ្មោះថាបានឆ្លង ឱឃៈនេះបានដោយពិត ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្ដីងឿងឆ្ងល់ ។

(១៩១) អធិប្បាយពាក្យថា បុគ្គលគប្បីដឹងច្បាស់នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ ត្រង់ពាក្យថាព្រាហ្មណ៍ បានសេចក្ដីថា ដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌៧។ គឺបន្សាត់បង់ សក្កាយទិដ្ឋិ បន្សាត់បង់ វិចិកិច្ឆា បន្សាត់-បង់ សីលព្វតបរាមាសៈ បន្សាត់បង់ រាគៈ បន្សាត់បង់ ទោសៈ បន្សាត់បង់ មោហៈ បន្សាត់បង់ មានះ ។ លោកបានលះបង់នូវអកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្ដីសៅហ្មង នាំមកនូវភពថ្មីប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានផលជាទុក្ខ ជាទីតាំងនៃជាតិ ជរា មរណៈ តទៅ ។

(ទំព័រ១៧៤)ព្រះមានព្រះភាគបរមសាស្ដាទ្រង់ត្រាស់

បន្តទៀតថា នរៈណាជាអ្នកចេះដឹង អ្នកដល់នូវវេទក្នុងលោកនេះ បានស្រាយនូវការជាប់ជំពាក់នេះក្នុងភពតូច និងភពធំ តថាគត ពោលថា នរៈនោះជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះបានឆ្លងនូវ ជាតិ និង ជរា ។

(មេត្តគូបានប្រកាសខ្លួន) ដំណាលគ្នានឹងកាលជាទីចប់ព្រះគាថា ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

(១៩៩) ធោតកមាណព ទូលសួរព្រះមានព្រះភាគ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គ សម្តែងសេចក្តីនោះដល់ខ្ញុំព្រះអង្គ បពិត្រព្រះមហេសី ខ្ញុំព្រះអង្គ ប្រាថ្នា(ស្តាប់)ព្រះពុទ្ធដីការបស់ព្រះអង្គ (ព្រោះថា) បុគ្គលកាលបើបានស្តាប់ទេសនារបស់ព្រះអង្គហើយ នឹងសិក្សានូវការរំលត់ (កិលេស)របស់ខ្លួនបាន ។

(២០៤) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលធោតកៈ បើដូច្នោះ ចូរអ្នកធ្វើសេចក្តីព្យាយាមចុះ បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតីស្តាប់ទេសនាអំពីនេះហើយ នឹងសិក្សានូវការរំលត់(កិលេស) របស់ខ្លួនបាន។

(ទំព័រ១៨០) ពាក្យថា មានបញ្ញាចាស់ក្លា គឺមាន

បញ្ញាឆ្អិន ជាបណ្ឌិតមានប្រាជ្ញា មានការចេះដឹង មានញាណ ជាអ្នកប្រាជ្ញ មានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ៤គឺ បុគ្គលកំពុងចម្រើន កាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមានស្មារតី ។បេ។ ហេតុនោះ (ទើបទ្រង់ត្រាស់ថា) បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ។

(២០៨) អធិប្បាយពាក្យថា នឹងសិក្សាការរំលត់(កិលេស)របស់ខ្លួន ត្រង់ពាក្យថា នឹងសិក្សា បានដល់សិក្ខា៣ គឺ អធិសីលសិក្ខា១ អធិចិត្តសិក្ខា១ អធិប្បញ្ញាសិក្ខា១ ។បេ។ ពាក្យថា ការរំលត់(កិលេស)របស់ខ្លួន គឺ នឹងសិក្សាអធិសីលផង សិក្សាអធិចិត្តផង នឹងសិក្សាអធិប្បញ្ញាផង ដើម្បីការរំលត់រាគៈ ការរំលត់ទោសៈ ការរំលត់មោហៈ ការរំលត់កោធៈ ការរំលត់ឧបនាហៈ ។បេ។ (ទំព័រ១៨១) ដើម្បីការស្ងប់ រម្ងាប់ ស្ងប់រម្ងាប់ រំលត់ លះបង់ រម្ងាប់ នូវអភិសង្ខារ ជាអកុសលទាំងពួង នឹងពិចារណា សិក្សានូវសិក្ខា៣ នេះ នឹងដឹងសិក្សា ។បេ។ នឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា នឹងប្រព្រឹត្តសមាទាន នឹងប្រតិបត្តិសមាទាន ហេតុនោះ (ទ្រង់ត្រាស់ថា)នឹងសិក្សានូវការរំលត់(កិលេស)របស់ខ្លួនបាន។

(២០៩) ធោតកៈពោលថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាទេវតាក្នុងមនុស្សលោក ព្រះអង្គមិនមានកង្វល់ ជា

ព្រាហ្មណ៍ កំពុងប្រព្រឹត្ត បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គ សូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គ ដោះខ្ញុំព្រះអង្គឲ្យផុត ចាកសេចក្តីសង្ស័យទាំងឡាយ ។

(២១៤) ព្រះមានព្រះភាគបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលធោតកៈ តថាគតមិនដោះអ្នកណាមួយក្នុងលោកនេះ ដែលមានសេចក្តីសង្ស័យបានទេ ប៉ុន្តែកាលបើអ្នកបានដឹង ច្បាស់នូវធម៌ដ៏ ប្រសើរយ៉ាងនេះ នឹងឆ្លងឱឃៈនេះបាន ។

(២១៥) ពាក្យថា តថាគតមិនអាចដើម្បីដោះ អធិប្បាយថា តថាគត មិនអាចដោះអ្នក ស្រង់ឡើង ចេញអំពីសរ គឺសេចក្តីសង្ស័យបាន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដើម្បីដោះ យ៉ាងនោះ ។ មួយទៀត តថាគត មិនខ្វល់ខ្វាយ មិនខ្វល់ខ្វាយខ្លាំង មិនព្យាយាម មិនធ្វើសេចក្តីប្រឹងប្រែង មិនញុំាងឆន្ទៈ ឲ្យកើត (ដើម្បីដោះ) នូវពួកបុគ្គល មិនមានឆន្ទៈ មានសេចក្តីខ្ជិលច្រអូស មានសេចក្តីព្យាយាមថយចុះ មិនប្រតិបត្តិតាម ដោយធម្មទេសនាបានទេ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ គឺយ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដទៃណាមួយ អាចញុំាងបុគ្គលដទៃឲ្យរួចបានមិនមានទេ ត្រូវតែបុគ្គលទាំងនោះ រួចដោយសេចក្តីព្យាយាមដ៏តឹងរឹងរបស់ខ្លួន ដោយសេចក្តីប្រឹងប្រែងរបស់ខ្លួន គឺប្រតិបត្តិនូវសម្មាបដិបទា អនុលោមប្បដិបទា ដោយខ្លួនឯងទើបរួចបាន ។

(ទំព័រ១៨៩) ហេតុនោះ ទើបទ្រង់ត្រាស់ថា តថាគត មិនអាចដើម្បីដោះ យ៉ាងនេះខ្លះ ។ សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទៈ បុគ្គលនោះ លិចចុះក្នុងភក់ខ្លួនឯង នឹងស្រង់បុគ្គលដទៃ ដែលលិចចុះក្នុងភក់បាន ហេតុនេះមិនដែលមានទេ ម្នាលចុន្ទៈ បុគ្គលនោះ មិនបានទូន្មាន មិនបានប្រៀនប្រដៅ មិនបានរំលត់កិលេសដោយខ្លួនឯង នឹងអាចទូន្មានប្រៀនប្រដៅបុគ្គល ឬថាអាចញ៉ាំងកិលេស របស់បុគ្គលដទៃ ឲ្យរលត់បានហេតុនេះមិនដែលមានទេ ហេតុនោះ(ទើបទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ យ៉ាងនេះខ្លះ ។ មួយទៀត សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា៖

បុគ្គលធ្វើបាបដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង មិនធ្វើបាបដោយខ្លួនឯង រមែងស្អាតដោយខ្លួនឯង សេចក្តីបរិសុទ្ធ និង សេចក្តីមិនបរិសុទ្ធ មានចំពោះខ្លួន បុគ្គលដទៃ មិនគប្បីញ៉ាំងបុគ្គលដទៃឲ្យស្អាតបានទេ ។

ហេតុនោះ(ទើបទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ យ៉ាងនេះខ្លះ ។ មួយទៀត សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ព្រះនិព្វានក៏មាននៅស្រាប់ ទាំងផ្លូវទៅកាន់ព្រះនិព្វាន ក៏មាននៅស្រាប់ តថាគតជាអ្នកបបួល ក៏មាននៅស្រាប់(ទំព័រ១៩០) តែថាពួក

សាវ័ករបស់តថាគត ដែលតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ពួកខ្លះក៏បានសម្រេចព្រះនិព្វានជាទីបំផុតដោយពិត ពួកខ្លះក៏មិនបានសម្រេច ម្នាលព្រាហ្មណ៍ តថាគត និង ធ្វើដូចម្តេចក្នុងបុគ្គលពួកខ្លះ ម្នាលព្រាហ្មណ៍ ព្រះតថាគត ជាអ្នកប្រាប់ផ្លូវ បើគេសួរផ្លូវហើយ ទើបព្រះតថាគតប្រាប់បាន បុគ្គលកាលប្រព្រឹត្ត ប្រតិបត្តិដោយខ្លួនឯង គប្បីរួចបាន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតមិនអាចដោះ យ៉ាងនេះខ្លះ ។

(៣២០) ហេមកៈមានអាយុទូលសួរ ព្រះមានព្រះភាគដូច្នោះថា ក្នុងកាលមុនអំពីសាសនាព្រះគោតម ជនទាំងឡាយណា ព្យាករថា ហេតុធ្លាប់មានហើយដូច្នេះ នឹងមានដូច្នេះ ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ពាក្យទាំងអស់នេះជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនត្រេកអរ ក្នុងពាក្យនោះឡើយ ។

(៣២៧)-បពិត្រព្រះមុនី សូមព្រះអង្គសម្តែងធម៌សម្រាប់ដកចេញនូវតណ្ហា ជាធម៌ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិប្រព្រឹត្តឆ្លងនូវវិសត្តិកាតណ្ហាក្នុងលោក ដល់ខ្ញុំព្រះអង្គ ។ ពាក្យថា **ធម៌** របស់បទថា សូមព្រះអង្គសម្តែងធម៌ គឺសូមព្រះអង្គពោលប្រាប់សម្តែង បញ្ញត្ត ប្រកាសនូវធម៌ មានពីរោះបទខាងដើម មានពីរោះបទកណ្តាល មានពីរោះបទខាងចុង នូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌សព្វ

គ្រប់នូវសតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គៈ៧ មគ្គប្រកបដោយអង្គ៨ ដ៏ប្រសើរ ព្រះនិព្វាន និង បដិបទាជាដំណើរ ទៅកាន់ព្រះនិព្វាន ហេតុនោះ(លោកពោលថា)សូមព្រះអង្គសម្តែងធម៌ ដល់ខ្ញុំព្រះអង្គ ។ ពាក្យថា **តណ្ហា** បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ។

(៣៣០) ពាក្យថា ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិប្រព្រឹត្ត គឺធ្វើឲ្យជាក់ច្បាស់នូវធម៌ណា ត្រិះរិះធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងមិនទៀង ថាសង្ខារទាំងពួងជាទុក្ខ ថា ធម៌ទាំងពួងជាអនត្តា ។បេ។ ធ្វើឲ្យដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះមានការរលត់ទៅវិញជាធម្មតា ។

(៣៣១) ពាក្យថាឆ្លងវិសត្តិកាតណ្ហាក្នុងលោក សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាង តម្រេក តម្រេកដ៏មានកម្លាំង។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។

(៣៣២) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលហេមកៈ និព្វានបទ ជាធម្មជាតិមិនឃ្លៀងឃ្លាត ជាគ្រឿងបន្ទោបង់នូវឆន្ទរាគៈ ក្នុងអារម្មណ៍ទាំងឡាយ មានសភាពជាទីស្រឡាញ់

ដែលឃើញ ឮ ប៉ះពាល់ (ឬដឹងច្បាស់) ក្នុងលោកនេះ ។

(៣៣៣) ពាក្យ ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ ក្នុងលោកនេះ ត្រង់ពាក្យថា ដែលឃើញ គឺដែលឃើញដោយភ្នែក ។ ពាក្យថា ឮ គឺឮដោយត្រចៀក ។ ពាក្យថា ប៉ះពាល់ គឺប៉ះពាល់ គឺធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សដោយអណ្តាត ប៉ះពាល់ដោយកាយ ។ ពាក្យថា ដឹងច្បាស់ គឺដឹងដោយចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា)ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ក្នុងលោកនេះ ។

(ទំព័រ២៧៥) ព្រះមានព្រះភាគ បរមសាស្តាទ្រង់ត្រាស់ថា៖ ជនទាំងឡាយណា ដឹងនិព្វាននុ៎ះ ជាអ្នកមានសតិ មានធម៌ ឃើញហើយ រលត់កិលេសហើយ ជនទាំងនោះ ជាអ្នកស្ងប់ រម្ងាប់ សព្វកាល ឈ្មោះថា ឆ្លងនូវវិសត្តិកាតណ្ហាក្នុងលោកបាន ។

លុះចប់ព្រះគាថាហើយ ។បេ។ ហេមកមាណពប្រកាសខ្លួនថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

(៣៦២) កប្បមាណពមានអាយុ ទូលសួរព្រះមាន-ព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹងរបស់ពួកសត្វ អ្នកឋិតនៅក្នុងកណ្តាលនៃស្រះ

ដែលត្រូវជរា និង មច្ចុគ្របសង្កត់ ព្រោះឱឃៈជាភ័យធំកើតឡើងហើយ ចុះសេចក្តីទុក្ខ(ក្នុងស្រះ)នេះ មិនគប្បីមានតទៅទៀត ដោយប្រការណា សូមព្រះអង្គប្រាប់នូវទីពឹង ដល់ខ្ញុំព្រះអង្គ ដោយប្រការនោះ ។

(៣៦៣)- ពាក្យថា អ្នកឋិតនៅក្នុងកណ្តាលនៃស្រះ អធិប្បាយថា សង្សារ លោកហៅថា ស្រះ បានដល់ដំណើរមក ដំណើរទៅ ដំណើរទៅ និង មក កាល គតិ ភពតូចធំ ការចុតិផង ការចាប់កំណើតផង ការកើតផង ការបែកធ្លាយផង ជាតិផង ជរាផង មរណៈផង ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ ទាំងទីបំផុតខាងចុង ក៏មិនប្រាកដ ។ ពួកសត្វដែលឋិតនៅ តាំងនៅ ជាប់ស្អិតនៅកុះករ ជ្រុលជ្រប់ ចុះស៊ប់ក្នុងសង្សារតែត្រង់កណ្តាល ។

(ទំព័រ២៩៨) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកប្បៈ តថាគតនឹងប្រាប់អ្នក នូវទីពឹងរបស់ពួកសត្វ អ្នកឋិតនៅក្នុងកណ្តាលនៃស្រះ ដែលត្រូវជរា និង មច្ចុគ្របសង្កត់ ព្រោះឱឃៈជាភ័យធំ កើតឡើងហើយ ។

(៣៧៤) ការមិនកង្វល់ ការមិនប្រកាន់មាំ នុ៎ះឯងជាទីពឹង ឯទីពឹងក្រៅពីនេះ ពុំមានទេ តថាគតហៅនូវទីពឹងនោះថា និព្វាន ជាទីអស់ជរា និង មច្ចុ ដោយប្រការដូច្នោះ ។

(៣៧៥)-ពាក្យថា ការមិនកង្វល់ បានសេចក្តីថា កង្វល់គឺរាគៈ កង្វល់គឺទោសៈ កង្វល់គឺមោហៈ កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត ការលះបង់កង្វល់ ការរម្ងាប់កង្វល់ ការរលាស់កង្វល់ ការស្ងប់កង្វល់ អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការមិនកង្វល់ ។

(ទំព័រ៣០២) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា៖ ពួកជនណា ជាអ្នកមានសតិ ដឹងនូវទីពឹងនុ៎ះមានធម៌ឃើញហើយ ជាអ្នករំលត់ហើយ ពួកជននោះជាអ្នកមិនលុះអំណាចមារ ពួកជននោះ ជាអ្នកមិនដល់នូវភាពជាអ្នកបម្រើមារ ។

# ៩-អាយាចនវគ្គ

## មិដកលេខ ៣៤ ទំព័រ៩៤

(១១៦) ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈមាន-អាយុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយ-បង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះ-រាធៈមានអាយុ អង្គុយក្នុងទីដ៏សមគួរ ហើយក្រាបទូលព្រះមាន-ព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងចៀស ចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្ដៅ កិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ព្រោះបានស្ដាប់ ធម៌ណា របស់ព្រះមានព្រះភាគ សូមព្រះមានព្រះភាគ សម្ដែង ធម៌នោះ ដល់ខ្ញុំព្រះអង្គដោយសង្ខេប ។ ព្រះសាស្ដា ទ្រង់ ត្រាស់ថា ម្នាលរាធៈ មារណាដែលកើតមាន សេចក្ដីពេញចិត្ត ក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ ម្នាលរាធៈ ចុះអ្វីជាមារ ។ ម្នាលរាធៈ រូបជាមារ សេចក្ដីពេញចិត្តក្នុងមារនោះ អ្នកគួរ លះបង់ចេញ វេទនាជាមារ សេចក្ដីពេញចិត្តក្នុងមារនោះអ្នកគួរ លះបង់ចេញ ។ សញ្ញា ។ សង្ខារទាំងឡាយជាមារ សេចក្ដី ពេញចិត្តក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ វិញ្ញាណជាមារ សេចក្ដីពេញចិត្តក្នុងមារ នោះ អ្នកគួរលះបង់ចេញ ។

(ទំព័រ៩៥) ម្នាលរាធៈ មារណាដែលកើតមានសេចក្ដី

ពេញចិត្ត ក្នុងមារនោះ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។

(១១៨) - **យំ ខោ រាធ អនិច្ចំ** ។

ម្នាលរាធៈ អនិច្ចៈណា ដែលកើតមាន ។

(១១៩) - **យោ ខោ រាធ អនិច្ចធម្មោ** ។

ម្នាលរាធៈ អនិច្ចធម៌ណា ។

(១២០) - **យំ ខោ រាធ ទុក្ខំ** ។

ម្នាលរាធៈ ទុក្ខណា ។

(១២១) - **យោ ខោ រាធ ទុក្ខធម្មោ** ។

ម្នាលរាធៈ ទុក្ខធម៌ណា ។

(១២២) - **យោ ខោ រាធ អនត្តា** ។

ម្នាលរាធៈ អនត្តាណា ។

(១២៣) - **យោ ខោ រាធ អនត្តធម្មោ** ។

ម្នាលរាធៈ អនត្តធម៌ណា ។

(១២៤) - **យោ ខោ រាធ ខយធម្មោ ។**

ម្នាលរាធៈ ខយធម៌ណា ។

(១២៥) - **យោ ខោ រាធ វយធម្មោ ។**

ម្នាលរាធៈ វយធម៌ណា ។

(១២៦) **យោ ខោ រាធ សមុទយធម្មោ តត្រ តេ ឆន្ទោ បហាតព្វោតិ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។**

ម្នាលរាធៈ សមុទយធម៌ណា ដែលកើតមានសេចក្តីពេញចិត្តក្នុងសមុទយធម៌នោះ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកអរ អ្នកគួរលះបង់ចេញ ។ សេចក្តីត្រេកត្រអាល អ្នកគួរលះបង់ចេញ ។

# ១០- ឥទប្បច្ចយតា

## ខ្សែអាត់សំឡេងធម៌

លោកគ្រូជាម្ចាស់បានសម្ដែង ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា៖ **ឥទប្បច្ចយតា** គឺជា (អាទិ) នៃព្រហ្មចរិយធម៌ (អាទិគឺ ដើមដំបូង) ដែលប្រព្រឹត្តទៅដើម្បី អរិយមគ្គ អរិយផល ដោយអាស្រ័យការស្ដាប់ព្រះធម៌ យល់ក្នុង **ឥទប្បច្ចយតា** ឃើញការ ប្រព្រឹត្តទៅក្នុងសង្ខារធម៌ ។ ព្រះអង្គទ្រង់ដាស់តឿនភិក្ខុថា ម្នាលភិក្ខុ ចូរអ្នកទន្ទេញឲ្យចាំនូវដំណើរនៃសង្ខារធម៌ដែលប្រព្រឹត្តទៅនេះ ព្រមទាំងការវិនាសទៅនៃដំណើរសង្ខារ-ធម៌នេះចុះ ។ ភិក្ខុកាលដែលមានការប្រព្រឹត្តទៅដោយធម៌បដិ-បត្តិគឺ សតិប្បដ្ឋាន៤ គឺវិបស្សនា ព្រោះបានយល់ទៅលើ **ឥទប្បច្ចយតា** ។

ការអប់រំចិត្ត អប់រំសតិ ការមានសតិរលឹកដឹងទាន់ទល់គ្នានឹងសភាវៈដែលកំពុងប្រាកដ ព្រមទៅដោយការយល់ត្រូវ មិនចង់កែប្រែសភាវៈ តែក្រេបជញ្ជក់នូវសេចក្ដីពិតនៃស-ភាវៈនោះដោយបញ្ញា សូម្បីសភាវៈនោះមានសភាពបែបណាក៏ដោយ។ ជារូបធម៌ឬជានាមធម៌ ជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍ វិបស្សនាក្រេបជញ្ជក់តែសភាពពិត នៃសភាវៈនោះតែប៉ុណ្ណោះ មិនប្រព្រឹត្តទៅដើម្បីទោមនស្ស ដើម្បីក្រេវក្រោធ ដើម្បីប្រទូស

នឹងសភាវៈណាមួយឡើយ ឬថា ដើម្បីផ្លាស់ប្តូរនូវសភាវៈណាមួយផ្សេងៗ ឲ្យបាននូវទីពឹងនោះក៏ទេដែរ គឺមានចិត្តស្ងប់រម្ងាប់ចំពោះសភាវៈដែលប្រព្រឹត្តទៅតាមហេតុ ទៅតាមបច្ច័យ **ឥទប្បច្ចយតា** នៃសភាវៈប្រាកដឡើង វិបស្សនាបញ្ញា គ្រេបយកតក្ខតា នៃសភាវៈនោះ ដើម្បីជាការជាក់ច្បាស់នូវភាពពិតនៃសភាវៈនោះ ច្រើនឡើងៗ នេះជាដំណើរនៃការប្រតិបត្តិ ។

ការសិក្សាបដិបត្តិព្រះធម៌ក្នុងព្រះពុទ្ធសាសនា សំខាន់គឺគប្បីសិក្សាឲ្យយល់ច្បាស់ពីរូបធម៌ និង នាមធម៌ ហើយចែកឲ្យដាច់នូវរូបធម៌ និង នាមធម៌ (នេះជាការអប់រំសតិប្បដ្ឋាន) បញ្ញាថ្នាក់ស្តាប់ មិនអាចចែកបានទេ ទាល់តែអាស្រ័យបញ្ញាថ្នាក់បដិបត្តិ ដែលជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ បុគ្គលអ្នកបដិបត្តិអាចរលឹកដឹង រូបធម៌ ដែលប្រាកដឡើងជាធាតុមិនដឹងនូវអារម្មណ៍ ឯនាមធម៌ប្រព្រឹត្តទៅដើម្បីដឹងនូវអារម្មណ៍ គឺដឹងនូវរូបារម្មណ៍ អារម្មណ៍គឺរូបបានដល់វណ្ណរូប មានពណ៌ខៀវលឿង ជាដើម១ សទ្ទារម្មណ៍ អារម្មណ៍គឺសំឡេង១ គន្ធារម្មណ៍ អារម្មណ៍ គឺក្លិន១ រសារម្មណ៍ អារម្មណ៍គឺរស១ ផោដ្ឋព្វារម្មណ៍ អារម្មណ៍ គឺការក្តៅ ត្រជាក់ តឹង កម្រើក ញ័រ១ ធម្មារម្មណ៍ អារម្មណ៍គឺធម៌ បានដល់ធម៌៦ គឺ បសាទរូប១ សុខុមរូប១ ចិត្ត១ ចេតសិក១ និព្វាន១ បញ្ញត្តិ១ ។ ធាតុដឹង គឺជានាមធម៌ ធាតុដឹងនេះដាច់ ដោយឡែកអំពីរូប ដោយអាស្រ័យបញ្ញាចែក

រូបធម៌ និង នាមធម៌ បញ្ញាចែករូបដោយឡែកអំពីនាមតាមសេចក្តីពិត ព្រោះសតិរលឹករឿយៗ ដឹងរូបធម៌ និង នាមធម៌ដូច្នេះឯង ។ ព្រោះហេតុដូច្នេះ ការដែលបុគ្គលបដិបត្តិ ដើម្បីចែករូបធម៌ និង នាមធម៌ រហូតដល់ឃើញសភាពនៃរូបធម៌ និង នាមធម៌ ទៅគ្រប់ពេលដែលកើត ខណៈនោះបុគ្គលអ្នកបដិបត្តិនឹងបាននូវបញ្ញា ឃើញសភាពដែលឥតខ្លឹមសារគឺអនត្តា ក្នុងកាលនោះ គឺសមគួរដល់ហេតុ ។ ប៉ុន្តែធម្មជាតិពោរពេញដោយអាថ៌កំបាំង ទើបបិទបាំងសត្វលោកដោយរនាំងគឺអវិជ្ជា ទើបសត្វលោកដ៏ច្រើនមិនដឹងក៏ប្រកាន់មាំថា ខ្លួនអាត្មាអញមាន តែតាមពិតសត្វលោក គ្រាន់តែជារបស់សន្មតតែប៉ុណ្ណោះ ខ្លួនអាត្មាអញខ្លួនឯង យើងគេនោះមិនមានទេ ។ ដូច្នេះ ដើម្បីបើកនូវរនាំងគឺអវិជ្ជា ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមាននូវសេចក្តីព្យាយាម ត្រូវព្យាយាមប្រព្រឹត្តតាមធម៌ តាមវិន័យ ក្នុងធម៌ ក្នុងវិន័យ ដែលតថាគតបានបញ្ញត្តទុកហើយ ដោយប្រពៃ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុកាលបើមានកាយខ្ជាប់ខ្ជួន មានចិត្តខ្ជាប់ខ្ជួន ទោះបីឈរ អង្គុយ ឬ ដេក តែងតែតម្កល់ សតិនុ៎ះ ភិក្ខុនោះ គប្បីបានគុណវិសេសមានទីបំផុតខាងដើម លុះបានគុណវិសេសខាងដើមហើយ ក៏ដល់នូវការមិនជួបប្រទះមច្ចុរាជ ។

# ១១- ជំនួយសតិភាគទី២

## សតិប្បដ្ឋាន

(ទំព័រ៦១) ធម៌ដែលត្រូវដឹង ដែលត្រូវត្រាស់ដឹង គឺបរមត្ថធម៌ បុគ្គលដែលកើតរោគបដិបត្តិធម៌ តែងចង់បានធម៌ដោយពុំដឹងថា តើអ្វីជាធម៌ដែលត្រូវដឹង ឬដែលត្រូវត្រាស់ដឹង ព្រោះតែមិន ដឹងធម៌ ទើបចង់បានធម៌ ។

ការចង់បានអ្វីក៏ដោយ គួរតែអប់រំការរលឹកដឹងឲ្យឃើញច្បាស់ថា ការចង់បានជាបរមត្ថធម៌ ពុំមែនជាសត្វបុគ្គលតួខ្លួនយើងឡើយ ។

ពុំអាចឃើញធម៌ពិតបានឡើយ បើអ្វីៗក៏សុទ្ធតែប្រកាន់ថាជាខ្លួន ឬជារបស់ខ្លួន ។

ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ពួកធម៌ជាអព្យា-កតៈ ធម្មៈដោយសេចក្តីថា មិនមែនជាសត្វ មិនមែនជាតួខ្លួនយើងគេឡើយ ។

(ទំព័រ៦២)- ដូច្នេះ ការឃើញធម៌ គឺឃើញសភាវពិតជាបរមត្ថធម៌ ដូចជាចិត្តឃើញជាធម៌ ចិត្តឮជាធម៌ ។ល។ ចិត្តនឹកគិតជាធម៌ សុខវេទនា ទុក្ខវេទនា ជាធម៌ លោភៈជាធម៌ ទោសៈជាធម៌ ។ល។ និង ។ល។ ការឃើញធម៌ គឺឃើញ

សភាវពិតដែលកំពុងប្រាកដជាបរមត្ថធម៌ ពុំមែនជារបស់យើង ពុំមែនជាយើង ពុំមែនជាតួខ្លួនឡើយ ។

កាយនេះមិននៅយូរឡើយ តែវិញ្ញាណចុងក្រោយមកដល់ហើយ ក៏ឈប់ដឹងខ្លួនថាអញ ថាជារបស់អាត្មាអញទៀតហើយ ដូច្នេះ ដែលដឹងខ្លួនថាអញ គឺដោយសារមានវិញ្ញាណ ។ តែវិញ្ញាណពុំមែនជាតួខ្លួន សត្វបុគ្គល យើងគេឡើយ ព្រោះមិនទៀង ចក្ខុវិញ្ញាណមិនទៀង សោតវិញ្ញាណមិនទៀង ឃានវិញ្ញាណមិនទៀង ជិវ្ហាវិញ្ញាណមិនទៀង កាយវិញ្ញាណមិនទៀង មនោវិញ្ញាណមិនទៀង របស់ណាមិនទៀង មានការអស់ទៅបាត់ទៅ របស់នោះត្រឹមតែជាផលរបស់បច្ច័យ មិនមែនជាយើង មិនមែនជាខ្លួនរបស់យើងឡើយ ។ បើវិញ្ញាណមិនមែនជាខ្លួនរបស់យើងហើយនោះ អារម្មណ៍របស់វិញ្ញាណ ក៏សម្រាប់តែវិញ្ញាណដឹងតែប៉ុណ្ណោះ បញ្ញាឃើញច្បាស់នូវវិញ្ញាណផង ឃើញច្បាស់នូវអារម្មណ៍របស់វិញ្ញាណផង ក៏មិនមានការប្រកាន់ថា អ្វីៗក្នុងលោកជារបស់យើង ជាយើង ជាខ្លួនរបស់យើងឡើយ។

(ទំព័រ៦៧-៦៨-៦៩) ព្រោះចក្ខុសម្ផស្សជាបច្ច័យទើបវេទនា សញ្ញា សង្ខារ វិញ្ញាណ កើតឡើងមានរូបជាអារម្មណ៍ សត្វក្នុងលោកភ្នែកមិនមានទេ ។

ព្រោះសោតសម្ផស្សជាបច្ច័យទើប វេទនា សញ្ញា សង្ខារ វិញ្ញាណ កើតឡើងមានសំឡេងជាអារម្មណ៍ សត្វក្នុងលោកត្រចៀកមិនមានទេ ។

ព្រោះឃានសម្ផស្សជាបច្ច័យទើប វេទនា សញ្ញា សង្ខារ វិញ្ញាណ កើតឡើងមានក្លិនជាអារម្មណ៍ សត្វក្នុងលោកច្រមុះមិនមានទេ ។

ព្រោះជិវ្ហាសម្ផស្សជាបច្ច័យទើប វេទនា សញ្ញា សង្ខារ វិញ្ញាណ កើតឡើងមានរសជាអារម្មណ៍ សត្វក្នុងលោកអណ្តាតមិនមានទេ ។

ព្រោះកាយសម្ផស្សជាបច្ច័យទើប វេទនា សញ្ញា សង្ខារ វិញ្ញាណ កើតឡើងមានផោដ្ឋព្វៈជាអារម្មណ៍ សត្វក្នុងលោកកាយមិនមានទេ ។

ព្រោះមនោសម្ផស្សជាបច្ច័យទើប វេទនា សញ្ញា សង្ខារ វិញ្ញាណ កើតឡើងមានធម៌ផ្សេងៗជាអារម្មណ៍ សត្វក្នុងលោកចិត្តមិនមានទេ ។

ម្នាលមារ អ្នកឃើញនូវអ្វីថាជាសត្វ ក្នុងគំនរនៃសង្ខារធម៌ ព្រោះខ្សែតំណនៃខន្ធ ធាតុ អាយតនៈ ទើបហៅថាសង្ខារ។ ព្រោះគំនរនៃខន្ធ ធាតុ អាយតនៈ ទើបហៅថា សង្សារសាគរ ។

ព្រោះការប្រជុំរួមនៃខន្ធ ទើបហៅថាសត្វ ។

នៅពេលដែលនឹកគិត ឬដឹងថារបស់នេះ របស់នោះគឺគ្រាន់តែជាមនោវិញ្ញាណប៉ុណ្ណោះ មានសតិរលឹក មានបញ្ញា ក៏មិនបានប្រកាន់ថាខ្លួនយើង ឬថាជាសត្វបុគ្គលអ្វីឡើយ ។

ការចេញចាកអំពីលោកនេះ គឺត្រូវពឹងលើបញ្ញារបស់ខ្លួនឯងទាំងស្រុង ដោយការដឹងច្បាស់នូវលោកថា សូន្យ គឺសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ។

លោកគ្រូជាម្ចាស់ តែងតែសម្តែងជារឿយៗ សូមពុទ្ធបរិស័ទមានសេចក្តីព្យាយាម ព្យាយាមក្នុងការស្តាប់នូវព្រះធម៌ស្តាប់ដោយគោរព ស្តាប់ដោយល្អ រមែងបាននូវបញ្ញា (សុតមយបញ្ញា) បញ្ញាកើតពីការស្តាប់ ។ ពេលកំពុងស្តាប់គឺកំពុងអប់រំបញ្ញា បញ្ញាបានឃើញធម៌ គឺឃើញបដិច្ចសមុប្បាទធម៌ បញ្ញាខ្លាំងក្លា បន្ទាប់ពីឃើញបដិច្ចសមុប្បាទធម៌ទៅ គឺឃើញអរិយសច្ចធម៌ គឺបន្ទាប់ពីឃើញបដិច្ចសមុប្បាទធម៌ និង ពីព្រោះបញ្ញាឃើញបដិច្ចសមុប្បាទធម៌ តាំងពីលោកិយ រហូតដល់លោកុត្តរ នៅក្នុងរឿងហេតុផល ។ ព្រោះអវិជ្ជាមិនដឹងនាមរូបទើបនាំឲ្យមានការតាក់តែងនូវភព ដែលជាឧបបត្តិភព ៣១ ភព ។

បញ្ញាឃើញអភិសង្ខារគឺកម្ម ដែលកើតមានព្រោះអវិជ្ជា

ឃើញការអស់ទៅនៃកម្មភព និង ឧបបត្តិភពព្រោះអស់អវិជ្ជា ។

បញ្ញាមានប្រយោជន៍ដ៏សំខាន់ណាស់ ជាពិសេសចំពោះពុទ្ធបរិស័ទ ដូច្នេះទើបពុទ្ធបរិស័ទមិនគប្បីមានសេចក្តីប្រមាទបានឡើយ មិនអាចថា មិនព្យាយាមក្នុងការស្តាប់បានឡើយ ព្រោះបញ្ញាអាចកើតបាន ចម្រើនបានអាស្រ័យការស្តាប់ ស្តាប់ហើយយកមកគិត (ចិន្តាមយបញ្ញា បញ្ញាកើតពីការគិត) គិតហើយភាវនា (ភាវនាមយបញ្ញា បញ្ញាកើតពីការភាវនា) ភាវនាគឺយករឿងដែលបានស្តាប់ បានគិតហើយនោះមកអនុវត្ត (បដិបត្តិ) បើជាវិបចិតញ្ញូបុគ្គល ក៏ត្រូវអាស្រ័យការស្តាប់ ការបានពន្យល់ច្រើន មានព្យាយាមខ្លាំង និង អាចយល់ដឹងនូវធម៌បាន បុគ្គលនេះ (ក្នុងបុគ្គលប្បញត្តិ) ជាផ្កាឈូកប្រភេទទី២ ដែល ដុះឡើងមកល្មមស្មើទឹក និង អាចរីកបានក្នុងព្រឹកថ្ងៃនេះ ឬក្នុងព្រឹកថ្ងៃស្អែក ។ បើជា**នេយ្យបុគ្គល** ក៏ត្រូវអាស្រ័យការស្តាប់យ៉ាងច្រើន ព្យាយាមយ៉ាងខ្លាំង ជាបុគ្គលដែលព្រះធម៌ល្មមអាចណែនាំបាន ជាប្រភេទផ្កាឈូកទី៣ ដុះនៅក្រោមទឹកនឹងអាចរីកបានក្នុងថ្ងៃមួយ ។ បើជា **បទបរមបុគ្គល** សូម្បីមានឧបនិស្ស័យជាអ្នកបានស្តាប់ហើយ តែទោះបីព្យាយាមខំស្តាប់ច្រើនយ៉ាងណា ក៏មិនអាចយល់ដឹងធម៌បាន គឺគ្រាន់តែបានឮ (កុសលថ្នាក់ឮ) ប៉ុណ្ណោះ ប្រៀបដូចវែកដែលឆ្លងកាត់សម្ល តែមិនដឹងរសជាតិនៃសម្លឡើយ ។ បុគ្គលនេះជា

ផ្កាឈូកប្រភេទទី៤ លិចនៅក្នុងដី អាចនឹងដុះឡើងផុតអំពីដី ឬក៏អាចជាចំណីត្រី និង អណ្តើកប៉ុណ្ណោះ ។

ប៉ុន្តែបញ្ញាទាំងឡាយ ដែលអាចកើតឡើងបាន ក៏ត្រូវអាស្រ័យបច្ច័យឲ្យកើតដែរ ។ ពុទ្ធបរិស័ទដែលបានស្តាប់យល់ គឺយល់អំពី**ធម្ម** ដែលជាទីតាំងនៃសតិរលឹកដឹង ។ គឺរលឹកដឹងទាន់ពេល **ធម្ម** កំពុងប្រាកដ ឃើញថានេះមិនមែនជាតួខ្លួនយើងទេ ។ ការស្តាប់ដោយល្អ សិក្សាដោយល្អ បានយល់ត្រូវ (គឺសម្មាទិដ្ឋិ) បានត្រាស់ដឹងធម៌ដោយបញ្ញាដ៏ប្រពៃ ឃើញសតិក៏ជា **អនត្តា** មិនមានការបង្គាប់បញ្ជាអំពីអ្នកណាឡើយ ។ **សព្វេ ធម្មា អនត្តា** ធម្មទាំងពួងជាអនត្តា ។

(បិដកលេខ ៣៤ ទំព័រ ១៤៨) ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានអ្វីហ្ន៎ ព្រោះតែអាស្រ័យអ្វី ប្រកាន់អ្វី ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បន្ទាប់អំពីសេចក្តីស្លាប់ទៅ ខ្លួននឹងមិនទុក្ខ មិនសុខ ទាំងមិនមានរោគ ។ បពិត្រ ព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំ មានព្រះមានព្រះភាគជាមូល ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានរូបព្រោះតែអាស្រ័យរូប ប្រកាន់រូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា បន្ទាប់អំពីសេចក្តីស្លាប់ទៅ ខ្លួននឹងមិនទុក្ខ មិនសុខ ទាំងមិនមានរោគ ។ កាលបើមានវេទនា។បេ។ កាលបើមានសញ្ញា ។ កាលបើមានសង្ខារទាំងឡាយ ។ កាលបើមានវិញ្ញាណ ប្រកាន់

វិញ្ញាណ ទើបទិដ្ឋិ កើតឡើង យ៉ាងនេះថា បន្ទាប់អំពីសេចក្តីស្លាប់ ខ្លួននឹងមិនទុក្ខ មិនសុខ ទាំងមិនមានរោគ ។

(បិដកលេខ៣៣ ទំព័រ៣៨៦) ជិតក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវកិរិយាអស់ទៅនៃអាសវៈ ចំពោះបុគ្គលដែលដឹងច្បាស់ ឃើញច្បាស់ មិនពោលចំពោះបុគ្គលដែលមិនដឹងច្បាស់ មិនឃើញច្បាស់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ រមែងមានដល់បុគ្គលដែលដឹងអ្វី ឃើញអ្វី ។ (គឺដល់បុគ្គលដែលដឹង ដែលឃើញ) ថារូបដូច្នេះ ថាហេតុឲ្យកើតឡើងនៃរូបដូច្នេះ សេចក្តីអស់ទៅនៃរូបដូច្នេះ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ ដូច្នេះ ហេតុឲ្យកើតឡើងនៃ វេទនា សញ្ញា សង្ខារ វិញ្ញាណ ដូច្នេះ ដឹងសេចក្តីអស់ទៅនៃ វេទនា សញ្ញា សង្ខារ វិញ្ញាណ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ រមែងមានដល់បុគ្គលដែលដឹងយ៉ាងនេះ ឃើញយ៉ាងនេះឯង ។

(បិដកលេខ៣៣ ទំព័រ៥៧ ភារវគ្គ) ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវភារៈ[១] ផង នូវអ្នកដែលនាំភារៈផង នូវការប្រកាន់មាំនូវភារៈផង នូវការដាក់ចុះនូវភារៈផង ដល់អ្នកទាំងឡាយ អ្នកទាំង-

(១)ភារៈ ប្រែថាធ្ងន់ គឺលំបាកនឹងរក្សា មានឲ្យដើរ អង្គុយ ដេក ប្រដាប់ ស៊ី ផឹក ជាដើម(អដ្ឋកថា)។

ឡាយចូរស្តាប់នូវព្រះធម៌នោះចុះ ។ បេ។ ទើបទ្រង់មានព្រះបន្ទូលសួរ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចឈ្មោះថាភារៈ ។ គប្បីឆ្លើយថា ឧបាទានក្ខន្ធទាំង៥ ។

(៥០)-ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ឈ្មោះថាអ្នកនាំនូវភារៈ។ គប្បីឆ្លើយថា បុគ្គល ។ គឺអ្នកមានអាយុនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា អ្នកនាំនូវភារៈ ។

(៥១)-ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ឈ្មោះថាការប្រកាន់មាំនូវភារៈ ។ តណ្ហាដែលនាំឲ្យកើតក្នុងភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយក្នុង អារម្មណ៍នោះៗជាប្រក្រតី ។ តណ្ហានោះ គឺកាមតណ្ហា១ ភវតណ្ហា១ វិភវតណ្ហា១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការ ប្រកាន់មាំនូវភារៈ ។

(៥២)-ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ឈ្មោះថា ការដាក់ចុះនូវភារៈ ។ សេចក្តីវិនាស និង សេចក្តីរលត់ មិនមានសេសសល់ កិរិយាលះបង់ កិរិយារលាស់ចោល កិរិយារួចស្រឡះ ការមិនមានអាល័យក្នុងតណ្ហានោះ ឯណា ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការដាក់ចុះនូវភារៈ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ នូវព្រះពុទ្ធដីកានេះហើយ លុះព្រះសុគតសាស្តា

ត្រាស់នូវព្រះពុទ្ធដីកានេះរួចហើយ បន្ទាប់ពីនោះមកព្រះសាស្តា ទ្រង់ត្រាស់ នូវព្រះគាថានេះថា៖

(៥៣)- **ភារា ហវេ បញ្ចក្ខន្ធា ភារហារោ ច បុគ្គលោ**

**ភារាទានំ ទុក្ខំ លោកេ ភារនិក្ខេបនំ សុខំ**

**និក្ខិបិត្វា គរុំ ភារំ អញ្ញំ ភារំ អនាទិយ**

**សមូលំ តណ្ហំ អព្វុយ្ហ និច្ឆាតោ បរិនិព្វុតោតិ។**

(៥៣) បញ្ចក្ខន្ធជារបស់ធ្ងន់ដោយពិត បុគ្គលអ្នកនាំនូវភារៈគឺ បញ្ចក្ខន្ធក្តី ការប្រកាន់មាំនូវភារៈគឺបញ្ចក្ខន្ធក្តី តែងនាំមកនូវទុក្ខ ក្នុងលោក ការដាក់ចុះនូវភារៈ ជាហេតុនាំមកនូវសុខ លុះតែបុគ្គលដាក់ចុះនូវភារៈដ៏ធ្ងន់គឺបញ្ចក្ខន្ធចេញ មិនក្តួចកាន់នូវភារៈដទៃទៀត បានដកឡើងនូវតណ្ហាព្រមទាំងឫស ទើបជាអ្នកមិនមានសេចក្តីប្រាថ្នា ហើយបរិនិព្វាន ។

(បិដកលេខ៣៥ ទំព័រ១៥៥) ម្នាលភិក្ខុទាំងឡាយ បុគ្គលណា មិនសង្រួមក្នុងផស្សាយតនៈទាំង៦ បុគ្គលនោះរមែងដល់នូវសេចក្តីទុក្ខ ។ ពួកបុគ្គលណា បានសង្រួមនូវផស្សាយតនៈទាំង៦ នោះហើយ ពួកបុគ្គលនោះ ឈ្មោះថាមានសទ្ធាជាគម្រប់ពីរ កម្ចាត់បង់នូវកិលេស មានចិត្តមិនទទឹកដោយរាគៈ ។

(ទំព័រ១៥៨) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរគ្របសង្កត់នូវ រាគៈ ទោសៈ មោហៈ នោះ ចូរទៅឲ្យដល់ត្រើយនៃ ជាតិ និង មរណៈ គឺព្រះនិព្វាន ចុះ ។

**សូមអនុមោទនា**!

**៚ចប់៚**

# កាយក្នុងកាយ ចិត្តក្នុងចិត្ត

វេលាតែងតែកន្លងផុតទៅ អ្វីៗសល់នៅដូចជាយល់សប្តិ
សរសើរនិទ្រាខឹងស្រឡាញ់ស្អប់ គ្មានអ្វីគួរជាប់ជំពាក់និត្យនៅ។
អ្វីៗក្នុងលោកគ្រាន់តែសន្មត បរមត្ថបញ្ញត្តិហេតុផលសេចក្តី
សង្ខារធម៌សុទ្ធឥតមានបានអ្វី ខ្ញុំក្តីអ្នកក្តីវង្វេងព្រោះល្ងង់ ។
កាយនៅក្នុងកាយចិត្តនៅក្នុងចិត្ត ជាដីកាពិតអង្គព្រះសាស្តា
អ្នកមាននិស្ស័យគប្បីសិក្សា បដិបត្តិបូជា បូជាឧត្តម ។
វេលាអស់ពិតតែចិត្តសម្រេច បញ្ញាកាត់ផ្តាច់ខ្សែគឺតណ្ហា
ចិត្តរួចចាកទុក្ខផុតវដ្តសង្សារ ឆ្លងដល់ត្រើយមហាគឺព្រះនិព្វាន។

**ដោយខ្ញុំព្រះករុណា នាងខ្ញុំ ទ៉ាងស៊ីណា**

**ហៅ បងមុំ**

## នាមពុទ្ធបរិស័ទដែលមានសទ្ធាបរិចាគប្រាក់ បោះពុម្ពសៀវភៅ

| | |
|---|---|
| ១-ឧ.ស. មី វ៉ាង ព្រមទាំងបុត្រ និងចៅ | ២២៥$ |
| ២-លោក វ៉ាង សត្យា ភរិយា ឈារី បុត្រ katia | ២១១$ |
| ៣-ឧ.សិ. តោ សាហៀង បុត្រ | ២០០$ |
| ៤-ឧ.ស. ហាក់ ច័ន្ទសុផល និងឧ.សិ. វ៉ាង ស៊ីណា បុត្រ | ២០០$ |
| ៥-ពៅ ធា និង បុត្រ | ១១០$ |
| ៦-ឧ.ស. ហាក់ ម៉ុងហេង និង ឧ.សិ. លឹម សុខគឹម | ១០០$ |
| ៧-ឧ.សិ. វ៉ាង យ៉ុម និង កូនចៅ | ១០០$ |
| ៨-ឧ.សិ. ប៉ូ ហ៊ុច និង កូនចៅ | ១០០$ |
| ៩-លោក លី សូផាត និង ភរិយា វ៉ាង ចន្ថា បុត្រ | ១០០$ |
| ១០-ឧ.សិ. វ៉ាង សាវុធ | ១០០$ |
| ១១-លោក វ៉ាង កេណ្ឌឌី ភរិយា ជឹង ដូណ្ណា | ១០០$ |
| ១២-លោក វ៉ាង ពៅ ភរិយា ស្រីមុំ បុត្រ | ១០០$ |
| ១៣-NATATLIE KONG | ៦០$ |
| ១៤-ឧ.ស. ចឹក វន និង ឧ.សិ. យី សារី បុត្រ | ៥០$ |
| ១៥-ឧ.សិ. លី ប៉ូលីនស៊ីមប៉ូ | ៥០$ |

| | |
|---|---|
| ១៦-Brian Hac + Vihac + Caden +Zoey | ៣០$ |
| ១៧-Richard + Tia + 5R | ៣០$ |
| ១៨-ប៉ក់ ផល្លី | ២០$ |
| ១៩-លោក មាស ខាន់កាន់ស៊ូរី ភរិយា ច័ន្ទ តារា បុត្រ | ២០$ |
| ២០-អ៊ុំ ង៉ា កូនចៅ | ២០$ |
| ២១-លោក ជា ភក្តី ភរិយា សុជាតា | ២០$ |
| ២២-BRANDA TOR | ១០$ |
| ២៣-DAVIN TOR | ១០$ |
| ២៤-DANNE TOR | ១០$ |
| ២៥-MOLIDA TOR | ១០$ |
| ២៧-លោក ចំរើន បុត្រ | ១០$ |
| ២៩-ឧ.សិ. គឹម ម៉ាលី កូនចៅ | ៥$ |
| ៣០-លោក ចាន់ សុខុម ព្រមទាំងកូនចៅ | ៥$ |

# នាមពុទ្ធបរិស័ទអ្នកជួយពិនិត្យអក្ខរាវិរុទ្ធ និង
# កិច្ចការជាធម្មទាន